Disability Rights California

*គ្រោងការណ៍ការពារ & គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ា*
*ទូរសព្ទហៅឥតគិតថ្លៃ (800) 776-5746*

# កញ្ចប់ឯកសារសម្រាប់សវនាការរបស់មជ្ឈមណ្ឌលតំបន់

***ខែវិច្ឆិកា ឆ្នាំ 2015 ការបោះពុម្ពផ្សាយលេខ 5484.06***

ឯកសារទាំងនេះនឹងជួយឲ្យអ្នកត្រៀមរៀបចំខ្លួនសម្រាប់សវនាការរបស់មជ្ឈមណ្ឌលតំបន់បាន។ ឯកសារមគ្គុទេសក៍នេះអនុវត្តសម្រាប់អតិថិជននៃមជ្ឈមណ្ឌលដែលមានអាយុចាប់ពី 3 ឆ្នាំឡើងទៅ។

មានដំណើរការសវនាការផ្សេងមួយសម្រាប់អតិថិជននៃកម្មវិធី Early Start (អាយុបីឆ្នាំចាប់ពីពេលកើត)។ កម្មវិធី Early Start ផ្តល់នូវសេវាកម្ម និងជំនួយអន្តរាគមន៍ដំបូងៗសម្រាប់ដែលមានអាយុក្រោម 3 ឆ្នាំ។ កុមារមានសិទ្ធិទទួលបានអត្ថប្រយោជន៍ពីកម្មវិធី Early Start បាន ដោយសារការរីកចម្រើនកាយសម្បទាយឺតនៅផ្នែកនៃការចម្រើនគំនិតវិភាគ (ដំណើរដឹងក្តី), ការចម្រើនរាងកាយ, ការចម្រើផ្នែកភាសា និងការនិយាយ, ការចម្រើនផ្នែកទំនាក់ទំនងសង្គម ឬការចម្រើនផ្លូវចិត្ត ឬជំនាញជួយខ្លួនឯង។ សូមមើលឯកសារព័ត៌មានសំខាន់ៗអំពីអត្ថប្រយោជន៍នៃកម្មវិធី Early Start របស់យើងខ្ញុំ ដើម្បីស្វែងយល់អំពីសិទ្ធិស្នើឲ្យមានសវនាការរបស់នៅក្នុងកម្មវិធី Early Start។ សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធី Early Start និងសិទ្ធិរបស់អ្នក មើលទំព័រវិបសាយ: http://www.disabilityrightsca.org//pubs/F05701.pdf ហើយអានត្រង់ជំពូកទី 12 ដែលនិយាយអំពី*កម្មវិធីសិក្សាពិសេស*របស់គ្រោងការណ៍ការពារ & គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ា: ឯកសារណែនាំ*អំពីសិទ្ធិ និងទំនួលខុសត្រូវ*។

**ផ្នែកទីមួយ – ការប្តឹងតវ៉ាប្រឆាំងនឹងសេចក្តីសម្រេចរបស់មជ្ឈមណ្ឌលតំបន់:** ការណែនាំអនុវត្តន៍ជាក់ស្តែងជាជំហានៗចំពោះការប្តឹងតវ៉ាប្រឆាំងនឹងការបដិសេធផ្តល់ ការបញ្ចប់ ឬការកាត់បន្ថយអត្ថប្រយោជន៍នៃមជ្ឈមណ្ឌលតំបន់។

**ផ្នែកទីពីរ – ឧបសម្ព័ន្ធ:** គំនូសតាង, គំរូសំណុំឯកសារ និងសេចក្តីសម្រេចឲ្យមានសវនាការ។

ឯកសារណែនាំប្រើប្រាស់នេះ លើកយកមកនិយាយអំពីអ្នកដែលគេកំពុងបដិសេធ បញ្ចប់ ឬកាតបន្ថយអត្ថប្រយោជន៍របស់ខ្លួន ឬអ្នកដែលតំណាងឲ្យពួកគេដែលជា “រូបអ្នក”។

យើងខ្ញុំសង្ឃឹមថា អ្នកនឹងយល់ដឹងអំពីព័ត៌មានដ៏មានសារៈសំខាន់នេះ។ បើអ្នកមានសំណួរ ឬចម្ងល់ ឬចាំបាច់ត្រូវការជំនួយច្រើនទៀត សូមមេត្តាទាក់ទងគ្រោងការណ៍ការពារ & គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ាតាមទូរសព្ទដែលមានលេខ (800) 776-5746 ឬការិយាល័យការពារសិទ្ធិអតិថិជនតាមមូលដ្ឋានរបស់អ្នកដែលមានទូរសព្ទលេខ (800) 390-7032។

**តារាងមាតិកា**

**ជំពូកទី 1 – សេចក្តីផ្តើម** ........ 5
**ជំពូកទី 2 – នីតិវិធី ឬដំណើរការអង្គសវនការ** ........ 5
**ការជូនដំណឹងគ្រប់គ្រាន់** ........ 5
**ការដាក់ពាក្យសុំឲ្យមានសវនាការ** ........ 6
**ការបន្តទទួលបានអត្ថប្រយោជន៍ ឬសេវាកម្មរបស់អ្នកនៅខណៈពេលនៃការប្តឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) ("ជំនួយដែលមិនទាន់មានការទូទាត់" )** ........ 7
**ការជួបប្រជុំក្រៅផ្លូវការ** ........ 7
**ការសម្រុះសម្រួល** ........ 8
**សេចក្តីស្នើ (ញត្តិ)** ........ 9
**សវនការយុត្តិធម៌** ........ 9
**រយៈពេលនៃការបន្ត (ការលើកទៅពេលក្រោយ)** ........ 10
**ការបញ្ជូលគ្នា** ........ 11
**អ្នកបកប្រែផ្ទាល់មាត់** ........ 11
**លទ្ធភាពចេញចូលទីកន្លែងអង្គសវនការ** ........ 11
**ការទទួលបានចៅក្រមផ្សេង** ........ 12
**ជំពូកទី 3 – ការត្រៀមសម្រាប់សវនការ** ........ 13
**ការកំណត់លើហេតុផលផ្នែកច្បាប់របស់អ្នក** ........ 13
**ការត្រៀមរៀបចំភស្តុតាងរបស់អ្នក** ........ 13
**ការប្រមូលភស្តុតាងជាលាយលក្ខណ៍អក្សរ (សំណុំឯកសារ)** ........ 13
**ការត្រៀមរៀបចំសាក្សី** ........ 15
**ការផ្លាស់ប្តូរគ្នានូវបញ្ជីឈ្មោះសាក្សី និងសេចក្តីថ្លែងទៅវិញទៅមក** ........ 15
**ជំពូកទី 4 – កំឡុងពេល និងក្រោយសវនការ** ........ 16
**សេចក្តីថ្លែងបើក** ........ 16
**ការសួរចម្លើយសាក្សី** ........ 16
*សាក្សីរបស់មជ្ឈមណ្ឌលតំបន់* ........ 16
*សាក្សីផ្ទាល់ខ្លួនរបស់អ្នក* ........ 17

**សេចក្តីថ្លែងបិទ/សេចក្តីសង្ខេបបិទជាលាយលក្ខណ៍អក្សរ** ............................ 17
**ក្រោយសវនការ** ............................................................................ 18
**ផ្នែកទី 2: ឧបសម្ព័ន្ធ** ......................................................................... 19
**ឧបសម្ព័ន្ធ A: គំនូសតាងនៃចរន្តកាលវិភាគសម្រាប់សវនការយុត្តិធម៌** ......... 20
**ឧបសម្ព័ន្ធ B: គំរូសំណើសុំផ្លាស់ប្តូរចៅក្រម** .................................................. 23
**ឧបសម្ព័ន្ធ C: គំរូបញ្ជីឈ្មោះសាក្សី និងឯកសារភស្តុតាងរបស់អ្នកប្តឹងតវ៉ា** ...... 26
**ឧបសម្ព័ន្ធ D: គំរូសេចក្តីសង្ខេបបិទរបស់អ្នកប្តឹងតវ៉ា** .................................. 28
**ឧបសម្ព័ន្ធ E ៖ សេចក្តីសម្រេច ពីសវនការរដ្ឋបាល** ...................................... 36

## ជំពូកទី 1 – សេចក្តីផ្តើម

អ្នកមានសិទ្ធិត្រូវប្តឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) បាន ក្នុងករណីដែល:

1. អ្នកគឺជាអតិថិជននៃមជ្ឈមណ្ឌលតំបន់មួយដែលបានស្នើសុំអត្ថប្រយោជន៍ ឬសេវាកម្មថ្មីមួយ ហើយមជ្ឈមណ្ឌលតំបន់នោះបានឆ្លើយថា៖ “ទេ”;
2. មជ្ឈមណ្ឌលតំបន់ចង់កាត់បន្ថយ ឬដកហូតអត្ថប្រយោជន៍ដែលមានរួចហើយ; ឬ
3. មជ្ឈមណ្ឌលតំបន់និយាយថា អ្នកគ្មានសិទ្ធិទទួលបានអត្ថប្រយោជន៍។

ឯកសារណែនាំប្រើប្រាស់នេះ អាចផ្តល់ឲ្យអ្នកនូវព័ត៌មានអំពីរបៀបធ្វើការប្តឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) និងអ្វីដែលត្រូវរំពឹងទុកនៅកំឡុងពេលនៃដំណើរការប្តឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) បាន។ បើអ្នកកំពុងធ្វើការប្តឹងតវ៉ាប្រឆាំងនឹងការបដិសេធសិទ្ធិទទួលបាន (ចំណុចទី 3) សូមមើលកញ្ចប់ឯកសារសម្រាប់សវនការអំពីសិទ្ធិទទួលបានអត្ថប្រយោជន៍ពីមជ្ឈមណ្ឌលតំបន់យើងខ្ញុំ តាមតំណបន្ទាប់ http://www.disabilityrightsca.org/pubs/557301.pdf

អ្នកអាចចង់ស្នើសុំឲ្យមានសវនការមួយ បើអ្នកមិនយល់ស្របចំពោះការកាត់បន្ថយ ការកែប្រែ ឬការបដិសេធផ្តល់អត្ថប្រយោជន៍ ឬសេវាកម្មដែលអ្នកគិតថាអ្នកចាំបាច់ត្រូវការពីមជ្ឈមណ្ឌលតំបន់។ សវនការផ្លូវការមួយ មិនមែនដូចគ្នានឹងការទៅតុលាការទេ ហើយវាគ្មានអ្វីដែលត្រូវភ័យព្រួយទេ។ ជួនកាល សវនការផ្លូវការមួយត្រូវបានគេហៅថា៖ “សវនការយុត្តិធម៌”។ តាមធម្មតា សវនាការទាំងនេះត្រូវបានគេប្រារព្ធធ្វើឡើងនៅក្នុងបន្ទប់មួយដែលនៅក្នុង ឬជិតមជ្ឈមណ្ឌលតំបន់។ ចៅក្រមសម្រាប់សវនាការនេះ ត្រូវបានគេហៅថា៖ “ចៅក្រមច្បាប់រដ្ឋបាល”។

ផ្នែកស្តីពីសវនការខាងក្រោមពន្យល់ប្រាប់អំពីរបៀបដែលអ្នកអាចស្នើសុំឲ្យមានសវនាការមួយ និងនីតិវិធី ឬដំណើរការអង្គសវនការ។

## ជំពូកទី 2 – នីតិវិធី ឬដំណើរការអង្គសវនការ

### ការជូនដំណឹងគ្រប់គ្រាន់

បើមជ្ឈមណ្ឌលតំបន់ចង់បដិសេធ កាត់បន្ថយ ឬបញ្ឈប់អត្ថប្រយោជន៍ ឬសេវាកម្មមួយ មជ្ឈមណ្ឌលតំបន់ត្រូវកំណត់កាលវិភាគប្រជុំរបស់កម្មវិធីជំនួយសមត្ថភាពនៃបុគ្គលមានកម្សោយការចម្រើនខ្លួន និងក្រុមគ្រួសារ (IPP)។ អ្នកមានសិទ្ធិទទួលបានលិខិតជូនដំណឹងអំពីចំណាត់ការ (NOA) បើមជ្ឈមណ្ឌលតំបន់និយាយថា៖ “ទេ” ចំពោះអ្វីដែលអ្នកចង់បាន។ ការជូនដំណឹងរបស់មជ្ឈមណ្ឌលតំបន់ ត្រូវតែនិយាយប្រាប់អ្នកអំពីអ្វីដែលខ្លួនគ្រោងនឹងធ្វើ និងដែលច្បាប់អនុញ្ញាតឲ្យខ្លួនធ្វើសេចក្តីសម្រេចរបស់ខ្លួនបាន។ ព័ត៌មាននេះនឹងជួយឲ្យអ្នកសម្រេចបានថាតើអ្នក

ត្រូវប្ដឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) ឬយ៉ាងណា ហើយវានឹងជួយឲ្យអ្នកត្រៀមរៀបចំខ្លួនសម្រាប់សវនការរបស់អ្នកបាន។ លិខិតជូនដំណឹងត្រូវតែនិយាយប្រាប់អំពី:

- អ្វីដែលមជ្ឈមណ្ឌលតំបន់នឹងធ្វើ
- អ្វីដែលមជ្ឈមណ្ឌលតំបន់កំពុងធ្វើវា
- ពេលវេលាដែលមជ្ឈមណ្ឌលតំបន់ត្រូវធ្វើវា
- ច្បាប់ វិធានច្បាប់ ឬគោលនយោបាយដែលអនុញ្ញាតឲ្យពួកគេធ្វើវាបាន
- របៀប និងទីកន្លែងដែលត្រូវដាក់ពាក្យប្ដឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា)
- ពេលផុតកំណត់សម្រាប់ការដាក់ពាក្យប្ដឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា)
- ព័ត៍មានអំពីអ្វីដែលកើតឡើងនៅក្នុងដំណើរការប្ដឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា)
- របៀបពិនិត្យមើលឡើងវិញលើកំណត់ត្រារបស់មជ្ឈមណ្ឌលតំបន់របស់អ្នក និង
- កន្លែងដែលត្រូវទទួលបានជំនួយការពារសិទ្ធិ។

នៅពេលដែលអ្នកបានទទួល NOA ហើយ អ្នកអាចនឹងដាក់ពាក្យស្នើសុំឲ្យមានសវនការមួយបាន បើអ្នកមិនយល់ស្រប។ បើមជ្ឈមណ្ឌលតំបន់បដិសេធ កាត់បន្ថយ ឬបញ្ឈប់អត្ថប្រយោជន៍ ឬសេវាកម្មមួយដោយគ្មានការផ្ដល់លិខិតជូនដំណឹងដល់អ្នក អ្នកនឹងនៅតែអាចប្ដឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) បាន - អ្នកមិនចាំបាច់ត្រូវការមាន NOA មួយច្បាប់ដើម្បីប្ដឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) ទេ។ អ្នកគ្រាន់តែត្រូវបំពេញទម្រង់បែបបទសំណើឲ្យមានសវនការយុត្តិធម៌មួយដែលអាចរកឃើញមាននៅលើទំព័រដែលមានតំណបន្ទាប់ http://www.dds.ca.gov/Forms/FairHearing/DS1805.pdf។

## ការដាក់ពាក្យសុំឲ្យមានសវនាការ

ដើម្បីដាក់ពាក្យស្នើឲ្យមានសវនការបាន ចូរបំពេញ និងផ្ញើទម្រង់បែបបទសំណើឲ្យមានសវនការយុត្តិធម៌ដែលមជ្ឈមណ្ឌលតំបន់បានផ្ញើភ្ជាប់នឹង NOA របស់អ្នក។ ផ្ញើសំណើឲ្យមានសវនការរបស់អ្នកទៅកាន់មជ្ឈមណ្ឌលតំបន់របស់អ្នក។ បើអ្នកមិនប្រាកដអំពីអ្នកដែលត្រូវផ្ញើវាទៅនោះ ចូរផ្ញើវាទៅទាំងមជ្ឈមណ្ឌលតំបន់របស់អ្នក និងទាំងការិយាល័យសវនការផ្លូវការដោយសរសេរដូចតទៅ:Office of Administrative Hearings (ការិយាល័យទទួលបន្ទុកសវនការរដ្ឋបាល) មានអាសយដ្ឋាននៅ 2349 Gateway Oaks Drive, Suite 200, Sacramento, CA 95833 ឬទូរសារទៅលេខ (916) 376-6318។

## ការបន្តទទួលបានអត្ថប្រយោជន៍ ឬសេវាកម្មរបស់អ្នកនៅខណៈពេលនៃការប្តឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) (“ជំនួយដែលមិនទាន់មានការទូទាត់”)

បើមជ្ឈមណ្ឌលតំបន់ព្យាយាមផ្លាស់ប្តូរអត្ថប្រយោជន៍ ឬសេវាកម្មដែលអ្នកមាន ហើយនោះ អ្នកមានសិទ្ធិបន្តទទួលបានអត្ថប្រយោជន៍ ឬសេវាកម្មទាំងនោះដដែល នៅខណៈដែលអ្នកកំពុងប្តឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា)។ អ្នកត្រូវតែប្តឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) ក្នុងរយៈពេល 10 ថ្ងៃចាប់ពីកាលបរិច្ឆេទដែលអ្នកបានទទួល NOA របស់អ្នក ដើម្បីបន្តទទួលបានអត្ថប្រយោជន៍ ឬសេវាកម្មរបស់អ្នកដោយគ្មានការផ្លាស់ប្តូរ។ នេះត្រូវបានគេហៅថា៖ “ជំនួយដែលមិនទាន់មានការទូទាត់”។ បើអ្នកស្នើសុំអត្ថប្រយោជន៍ ឬសេវាកម្មថ្មីមួយ ហើយមជ្ឈមណ្ឌលតំបន់និយាយថា៖ “ទេ” អ្នកមិនមានសិទ្ធិទទួលបានជំនួយដែលមិនទាន់មានការទូទាត់ទេ។

## ការជួបប្រជុំក្រៅផ្លូវការ

នៅពេលដែលអ្នកដាក់ទម្រង់បែបបទសំណើឲ្យមានសវនការយុត្តិធម៌ អ្នកអាចស្នើសុំឲ្យមានការជួបប្រជុំក្រៅផ្លូវការ និង/ឬការសម្រុះសម្រួលមួយបាន នៅមុនពេលចាប់ផ្តើមសវនការ។ ការជួបប្រជុំក្រៅផ្លូវការនេះ គឺជាជំហានទីមួយនៅក្នុងដំណើរការអង្គសវនការ។ វាគឺជាកិច្ចប្រជុំមួយរវាងរូបអ្នក (និងតំណាងរបស់អ្នក បើអ្នកមានតំណាងម្នាក់) និងតំណាងរបស់មជ្ឈមណ្ឌលតំបន់មួយ។ គោលបំណង គឺដើម្បីដោះស្រាយបញ្ហា ឬយ៉ាងហោចណាស់កាត់បន្ថយបញ្ហាសម្រាប់អង្គសវនការ។ នេះគឺជាឱកាសរបស់អ្នកដើម្បីជួបជាមួយនឹងអ្នកគ្រប់គ្រងមជ្ឈមណ្ឌលតំបន់ ហើយបញ្ចុះបញ្ចូលគាត់ឲ្យផ្តល់ដល់អ្នកនូវអត្ថប្រយោជន៍ ឬសេវាកម្មដែលអ្នកចាំបាច់ត្រូវការ។ អ្នកមិនត្រូវមានការជួបប្រជុំក្រៅផ្លូវការទេ។ បើអ្នកស្នើសុំឲ្យមានការជួបប្រជុំមួយនោះ មជ្ឈមណ្ឌលតំបន់ត្រូវតែផ្តល់ឲ្យមានមួយលើក។ គំនូសតាងនៃចរន្តបន្ទាត់ពេលវេលានៃសវនការយុត្តិធម៌ មានការបញ្ចូលនៅក្នុងឧបសម្ព័ន្ធ A។

ក្នុងរយៈពេល 5 ថ្ងៃដែលធ្វើការក្រោយកិច្ចប្រជុំក្រៅផ្លូវការ មជ្ឈមណ្ឌលតំបន់ត្រូវតែផ្ញើឲ្យអ្នកនូវសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ (ដីកាសម្រេច) មួយច្បាប់។ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ (ដីកាសម្រេច) ត្រូវតែចុះនូវបញ្ហាដែលបានលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំនោះ។ ដីកាសម្រេចត្រូវនិយាយលើកឡើងអំពីសេចក្តីសម្រេចរបស់មជ្ឈមណ្ឌលតំបន់លើបញ្ហានីមួយៗ អង្គហេតុដែលទ្រទ្រង់សេចក្តីសម្រេចនីមួយៗ និងច្បាប់ បញ្ញត្តិច្បាប់ និងគោលនយោបាយដែលមជ្ឈមណ្ឌលតំបន់ធ្លាប់ធ្វើការសម្រេចចិត្តរបស់ខ្លួន។ លើសពីនេះ វាត្រូវតែមាននិយាយប្រាប់អ្នកអំពីរបៀបដែលអ្នកអាចប្តឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) ប្រឆាំងនឹងសេចក្តីសម្រេចនោះ។

បើអ្នកយល់ស្របតាមសេចក្តីសម្រេចរបស់មជ្ឈមណ្ឌលតំបន់ក្រោយកិច្ចប្រជុំផ្លូវការរបស់អ្នក អ្នកអាចនឹងដកសំណើសុំឲ្យមានសវនាការរបស់អ្នកបាន។ ធ្វើការនេះដោយបំពេញទម្រង់បែបបទសម្រាប់ "ការជូនដំណឹងអំពីដំណោះស្រាយ/សេចក្តីសម្រេច" ដែលមជ្ឈមណ្ឌលតំបន់បានផ្តល់ឲ្យ។ សេចក្តីសម្រេចនឹងចូលជាធរមានក្នុងរយៈពេល 10 ថ្ងៃក្រោយមជ្ឈមណ្ឌលតំបន់បានទទួលទម្រង់បែបបទសម្រាប់ "ការជូនដំណឹងអំពីដំណោះស្រាយ/សេចក្តីសម្រេច" ហើយ។

បើអ្នកមិនយល់ស្របតាមសេចក្តីសម្រេចរបស់មជ្ឈមណ្ឌលតំបន់ក្រោយកិច្ចប្រជុំផ្លូវការរបស់អ្នក អ្នកអាចបន្តជាមួយនឹងការសម្រុះសម្រួល ឬសវនាការដែលបានកំណត់កាលវិភាគទុកបាន។ អ្នកមិនត្រូវយល់ព្រមតាមសេចក្តីសម្រេចរបស់មជ្ឈមណ្ឌលតំបន់ទេ។

## ការសម្រុះសម្រួល

បើអ្នកមិនយល់ស្របតាមសេចក្តីសម្រេចក្រៅផ្លូវការទេនោះ ជំហានបន្ទាប់គឺការសម្រុះសម្រួល។ រូបអ្នក ឬមជ្ឈមណ្ឌលតំបន់អាចនឹងសម្រេចមិនចូលរួមក្នុងការសម្រុះសម្រួលបាន។ មជ្ឈមណ្ឌលតំបន់ជាច្រើនមិនចូលរួមទេ។ បើអ្នកស្នើសុំឲ្យមានការសម្រុះសម្រួលមួយ ហើយមជ្ឈមណ្ឌលតំបន់និយាយថា៖ "ទេ" ពេលនោះ ជំហានបន្ទាប់គឺសវនាការយុត្តិធម៌មួយ។

ការសម្រុះសម្រួលមួយ គឺជាកិច្ចប្រជុំដែលអ្នកជំនាញសម្រុះសម្រួលឯករាជ្យជួបប្រជុំជាមួយអ្នក និងតំណាងមជ្ឈមណ្ឌលតំបន់ម្នាក់។ វាប្រព្រឹត្តទៅក្នុងរយៈពេល 30 ថ្ងៃចាប់ពីការទទួលបានសំណើសុំឲ្យមានសវនាការរបស់អ្នក។ អ្នកសម្រុះសម្រួលនឹងព្យាយាមរកមើលដំណោះស្រាយសាមញ្ញៗដែលមានមូលដ្ឋានត្រឹមត្រូវ និងថ្មីៗ។ អ្នកសម្រុះសម្រួលគ្មានសិទ្ធិអំណាចបង្ខំឲ្យមានកិច្ចព្រមព្រៀងមួយឡើយ។ បើអ្នកឈានដល់កិច្ចព្រមព្រៀងមួយ អ្នកត្រូវចុះហត្ថលេខាលើឯកសារនៃកិច្ចព្រមព្រៀងនោះ ហើយដំណើរការប្តឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) ក៏នឹងឈប់ដែរ។ បើអ្នកមិនឈានដល់កិច្ចព្រមព្រៀងទេនោះ អ្នកត្រូវបន្តទៅកាន់សវនាការយុត្តិធម៌។

គ្រប់ៗគ្នាគប្បីគិតពិចារណាលើការប្រើវិធីសម្រាប់ការសម្រុះសម្រួល។ ជារឿយៗ ការសម្រុះសម្រួលគឺជាគំនិតល្អមួយ ពីព្រោះវាផ្តល់ឲ្យអ្នក និងមជ្ឈមណ្ឌលតំបន់នូវឱកាសមួយទៀតដែលត្រូវឈានដល់កិច្ចព្រមព្រៀងបាន។ យ៉ាងណាក៏ដោយ វាពិតជានឹងស៊ីពេលខ្លះៗដែរ។ អ្នកសម្រុះសម្រួលមានលក្ខណៈឯករាជ្យ ហើយនឹងព្យាយាមជួយឲ្យអ្នកឈានដល់កិច្ចព្រមព្រៀងមួយបាន។ បើទោះជាការសម្រុះសម្រួលមិនមានប្រសិទ្ធភាពសម្រាប់អ្នកក៏ដោយ ក៏អ្នកត្រូវមានព័ត៌មានច្រើនទៀតអំពីករណីរបស់មជ្ឈមណ្ឌលតំបន់ដែរ។ ព័ត៌មាននោះអាចនឹងជួយអ្នកនៅអង្គសវនាការរបស់អ្នកបាន។ បើអ្នកគិតថាគ្មានសង្ឃឹមចំពោះការឈានដល់កិច្ចព្រមព្រៀងមួយ អ្នកអាចនឹងសម្រេចថានឹងមិនសម្រុះសម្រួលបាន។ បញ្ហានេះត្រូវបានគេហៅថា៖

“ដំណើរបដិសេធការសម្រុះសម្រួល”។ ប៉ុន្តែមានមនុស្សជាច្រើនដែលគិតថាគ្មានសង្ឃឹមចំពោះការឈានដល់កិច្ចព្រមព្រៀងដែលបានបញ្ចប់ការឈានដល់កិច្ចព្រមព្រៀងតាមការសម្រុះសម្រួល។ បើរូបអ្នក ឬមជ្ឈមណ្ឌលតំបន់បដិសេធការសម្រុះសម្រួល ចូរធ្វើឲ្យប្រាកដថា អ្នកបានត្រៀមខ្លួនស្រេចបាច់សម្រាប់អង្គសវនការរបស់អ្នក។ អង្គសវនការរបស់អ្នកអាចនឹងមានការកំណត់កាលវិភាគឆាប់ៗជាងករណីដែលអ្នកទៅខាងការសម្រុះសម្រួល។

## សេចក្តីស្នើ (ញត្តិ)

សេចក្តីស្នើ (ញត្តិ) មួយ គឺជាសំណើទៅកានចៅក្រមច្បាប់រដ្ឋបាលឲ្យសម្រេចលើអ្វីមួយនៅមុនអង្គសវនការ។ ឧទាហរណ៍នៃសេចក្តីស្នើ (ញត្តិ) មានជាអាទិ៍ សេចក្តីស្នើ (ញត្តិ) ឲ្យបោះបង់ដោយផ្អែកលើលក្ខន្តិកៈពាក់ព័ន្ធការកម្រិតលក្ខខណ្ឌ ឬសេចក្តីស្នើ (ញត្តិ) ឲ្យធ្វើមោឃៈភាពលិខិតកោះហៅ។ អ្នកអាចដាក់សេចក្តីស្នើ (ញត្តិ) បាន។ មជ្ឈមណ្ឌលតំបន់ ក៏អាចដាក់សេចក្តីស្នើ (ញត្តិ) បានដែរ។

ច្បាប់ស្តីពីនីតិវិធីផ្លូវការ (APA) មិនប្រើចំពោះសវនការនៅមជ្ឈមណ្ឌលតំបន់ទេ តែវាអាចជាការណែនាំដ៏សំខាន់មួយសម្រាប់ការឆ្លើយតបនឹងសេចក្តីស្នើ (ញត្តិ) បាន។ គេអាចរកមើល APA បាន តាមតំណបន្ទាប់ http://www.dgs.ca.gov/oah/GeneralJurisdiction/APAHearings.aspx។

មជ្ឈមណ្ឌលតំបន់មួយចំនួន បានដាក់សេចក្តីស្នើ (ញត្តិ) ឲ្យបញ្ឈប់ករណីមួយ។ សេចក្តីស្នើ (ញត្តិ) ឲ្យបញ្ឈប់ ស្នើកុំឲ្យចៅក្រមអនុញ្ញាតឲ្យមានសវនការ ពីព្រោះអ្នកមិនមានសិទ្ធិស្នើឲ្យមានសវនការមួយបានទេ។ សេចក្តីស្នើ (ញត្តិ) ប្រភេទនេះ កម្រមានណាស់។ លើសពីនេះ វាមានលក្ខណៈផ្ទុយនឹងច្បាប់ដែលធានាសិទ្ធិស្នើឲ្យមានសវនការរបស់អ្នក។ ករណីលើកលែងតែមួយគត់ គឺនៅពេលដែលគ្មានបញ្ហាជាក់ស្តែងអ្វីទាំងអស់ (ឧទាហរណ៍) បើច្បាប់ចែងថា គ្មានបុគ្គលណាម្នាក់មានសិទ្ធិទទួលបានអត្ថប្រយោជន៍ ឬសេវាកម្មជាក់លាក់មួយតទៅទៀតបាន ដោយមិនគិតដល់តម្រូវការចាំបាច់របស់ពួកគេ។

## សវនការយុត្តិធម៌

ជំហានចុងក្រោយក្នុងដំណើរការប្តឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) គឺសវនការយុត្តិធម៌។ វាប្រព្រឹត្តទៅក្នុងរយៈពេល 50 ថ្ងៃបន្ទាប់ពីការទទួលបានសំណើសវនការរបស់អ្នក បើគ្មានអ្នកស្នើសុំការពន្យាដោយមានមូលហេតុត្រឹមត្រូវ។ អ្នក ហើយនិងមជ្ឈមណ្ឌលតំបន់ ត្រូវតែផ្ញើឲ្យគ្នាទៅវិញទៅមកឯកសារបញ្ជាក់ (ភស្តុតាង) និងបញ្ជីឈ្មោះសាក្សីក្នុងរយៈពេល 5 ថ្ងៃតាមប្រតិទិន មុននឹងដំណើរការអង្គសវនការយុត្តិធម៌របស់អ្នក។ សវនការនេះមានការប្រព្រឹត្តទៅនៅចំពោះមុខចៅក្រមច្បាប់រដ្ឋបាល (ALJ) ដែលមកពីការិយាល័យសវនការផ្លូវការ (OAH)។ នៅឯអង្គសវនការ

នេះ មជ្ឈមណ្ឌលតំបន់ត្រូវបង្ហាញករណីរបស់ខ្លួនជាមុន។ ALJ ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ (ដីកាសម្រេច) ក្នុងរយៈពេលប្រហែលជា 10 ថ្ងៃនៅបន្ទាប់ពីដំណើរការនៃអង្គសវនការនេះ។

## <u>រយៈពេលនៃការបន្ត (ការលើកទៅពេលក្រោយ)</u>

ទាំងរូបអ្នក ទាំងមជ្ឈមណ្ឌលតំបន់អាចនឹងស្នើសុំឲ្យមានការផ្លាស់ប្តូរកាលបរិច្ឆេទសវនការ ឬការសម្រុះសម្រួល។ ដើម្បីលើកសវនការទៅពេលក្រោយបាន អ្នកត្រូវដាក់ទម្រង់បែបបទ "សេចក្តីស្នើ (ញត្តិ) សុំរយៈពេលនៃការបន្តដំណើរការអង្គសវនការ និងសំបុត្របដិសេធពេលវេលា"។ នេះគឺជាតំណទៅកាន់ទំព័រនៃទម្រង់បែបបទសេចក្តីស្នើ (ញត្តិ):
http://www.documents.dgs.ca.gov/oah/forms/DDS_RFC_Form.pdf

ទម្រង់បែបបទនេះ មានចន្លោះមួយដែលអ្នកចាំបាច់ត្រូវពន្យល់អំពីមូលហេតុដែលអ្នកចាំបាច់ត្រូវពន្យាពេលសវនការ។ OAH នឹងអនុញ្ញាតលើរយៈពេលនៃការបន្តបាន ក្នុងករណីដែលមានការបង្ហាញច្បាស់លាស់អំពី "មូលហេតុត្រឹមត្រូវ"។ លើសពីនេះ អ្នកអាចភ្ជាប់ឯកសារមួយចំនួនដែលបម្រើឲ្យតម្រូវការចាំបាច់សម្រាប់រយៈពេលនៃការបន្តរបស់អ្នក។

ទម្រង់បែបបទនេះ ប្រាប់អ្នកឲ្យហៅទូរសព្ទទាក់ទងទៅតំណាងមជ្ឈមណ្ឌលតំបន់ ហើយសាកសួរថាតើគាត់នឹងឯកភាពឲ្យបន្តសវនការឬក៏អត់។ នៅក្នុងចន្លោះដែលទុកឲ្យ អ្នកត្រូវសរសេរឈ្មោះ និងលេខទូរសព្ទបុគ្គលិកមជ្ឈមណ្ឌលតំបន់ដែលបាននិយាយគ្នាជាមួយនឹងអ្នក។ បន្ទាប់មក សម្រេចថាតើបុគ្គលិកនោះបានឯកភាព ឬមិនឯកភាពលើសំណើរយៈពេលនៃការបន្ត។ អ្នកត្រូវសុំឲ្យបុគ្គលិកមជ្ឈមណ្ឌលតំបន់នោះផ្តល់នូវលេខទូរសារ ឬអាសយដ្ឋានអ៊ីម៉ែលដែលត្រូវផ្ញើទម្រង់បែបបទដែលបានបំពេញហើយទៅជូនគាត់ចុះហត្ថលេខា។

រូបអ្នក ឬតំណាងអ្នក ត្រូវចុះហត្ថលេខាលើផ្នែកដែលមានចំណងជើងថា៖ "សំបុត្របដិសេធពេលវេលាដែលកំណត់ដោយច្បាប់សម្រាប់សវនការយុត្តិធម៌ និងសេចក្តីសម្រេចដែលស្របតាមច្បាប់ Lanterman"។ ដើម្បីទទួលបានការអនុញ្ញាតលើរយៈពេលនៃការបន្ត អ្នកត្រូវតែយល់ព្រម "បដិសេធ" បន្ទាត់ពេលវេលានៃសវនការ។ នេះមានន័យថា អ្នកនឹងយល់ស្របឲ្យមានសវនការបានប្រព្រឹត្តទៅក្រោយរយៈពេល 50 ថ្ងៃបន្ទាប់ពីមានការទទួលបានសំណើឲ្យមានសវនការយុត្តិធម៌របស់អ្នកហើយ។

ត្រូវចងចាំចំពោះការផ្ញើទូរសារ ឬអ៊ីម៉ែលទម្រង់បែបបទនេះទៅកាន់តំណាងនៃមជ្ឈមណ្ឌលតំបន់ ហើយនិងសុំឲ្យគាត់ចុះហត្ថលេខា។ ក្រោយមានការចុះហត្ថលេខា

លើទម្រង់បែបបទនេះហើយ អ្នកត្រូវផ្ញើវាតាមទូរសារទៅកាន់ OAH។ ប្រើលេខទូរសារសម្រាប់កន្លែងដែលអង្គសវនការនឹងប្រព្រឹត្តទៅ:

| | |
|---|---|
| OAH Sacramento: | 916-376-6318 |
| OAH Los Angeles: | 916-376-6395 |
| OAH San Diego: | 916-376-6325 |
| OAH Oakland: | 916-376-6323 |

បើអ្នកមិនមានពេលគ្រប់គ្រាន់ដើម្បីផ្ញើសេចក្តីស្នើ (ញត្តិ) ជាលាយលក្ខណ៍អក្សរទេនោះ អ្នកអាចនឹងព្យាយាមការហៅទូរសព្ទទៅកាន់ OAH ហើយស្នើសុំរយៈពេលនៃការបន្ត។ ក្រោយរយៈពេលដែលអ្នកដាក់សេចក្តីស្នើ (ញត្តិ) ដើម្បីបន្តសវនការហើយនោះ អ្នកអាចពិនិត្យមើលលើវិបសាយ OAH ដើម្បីដឹងអំពីលក្ខខណ្ឌដែលគេអនុញ្ញាតចំពោះសេចក្តីស្នើ (ញត្តិ): http://www.dgs.ca.gov/oah/GeneralJurisdiction/Continuances.aspx

អ្នកនឹងចាំបាច់ត្រូវវាយបញ្ចូលលេខសំណុំរឿង OAH របស់អ្នក ប្រយោជន៍អនុវត្តការស្វែងរក។

## ការបញ្ចូលគ្នា

ការបញ្ចូលគ្នាគឺនៅពេលដែលករណីចាប់ពីពីរឡើងទៅដែលមានបញ្ហា ឬអង្គហេតុដូចគ្នាជារួមត្រូវបានគេលើកយកមកក្នុងអង្គសវនការដំណាលគ្នាដោយចៅក្រមដដែល។ អ្នកអាចស្នើសុំឲ្យមានការបញ្ចូលគ្នាបាន។ លើសពីនេះ OAH ក៏អាចស្នើឲ្យមានការបញ្ចូលរវាងករណីដែលមានចាប់ពីពីរឡើងទៅបានដែរ។ បើអ្នកមានអារម្មណ៍មិនស្រួលចំពោះការយល់ស្របឲ្យមានការបញ្ចូលគ្នានោះ អ្នកអាចនិយាយថា៖ "ទេ" បាន។ ចៅក្រមនឹងសម្រេចថាតើត្រូវបញ្ចូលគ្នារវាងករណីទាំងអស់ដោយផ្អែកលើច្បាប់ Lanterman និងការវិវត្តិនៃករណី។

## អ្នកបកប្រែផ្ទាល់មាត់

បើអ្នក ឬសាក្សីម្នាក់ចាំបាច់ត្រូវការអ្នកបកប្រែផ្ទាត់មាត់ម្នាក់ ចូរទាក់ទងទៅ OAH ភ្លាមៗ។ OAH នឹងផ្តល់អ្នកបកប្រែផ្ទាល់មាត់ដែលមានការបញ្ជាក់ទទួលស្គាល់ត្រឹមត្រូវដោយឥតគិតថ្លៃ។

## លទ្ធភាពចេញចូលទីកន្លែងអង្គសវនការ

ជនពិការត្រូវតែមានសិទ្ធិចេញចូលទីកន្លែងអង្គសវនការបាន។ អ្នកគប្បីសាកសួរទៅ OAH ជាមុន ដើម្បីឲ្យប្រាកដថា ទីកន្លែងអាចចេញចូលបាន។ បើមានជនពិការម្នាក់ដែលចាំបាច់ត្រូវការការយកចិត្តទុកដាក់សមស្របមួយដើម្បីឲ្យចូលរួមសវនការបាន ចូរទាក់ទងទៅ OAH ឲ្យបានឆាប់ៗតាមដែលអាចធ្វើទៅបាន ដើម្បីឲ្យ OAH អាចធ្វើការរៀបចំបាន។

**<u>ការទទួលបានចៅក្រមផ្សេង</u>**

ចៅក្រមមែនមានតែម្នាក់ទេ។ អ្នកចាំបាច់ត្រូវស្វែងយល់ដឹងអំពីចៅក្រមអ្នកសិននៅមុនសវនការ។ អ្នកអាចនឹងមានលទ្ធភាពទទួលបានចៅក្រមផ្សេងទៀត បើចៅក្រមដែលបានចាត់ឲ្យអ្នកមានប្រវត្តិលម្អៀង ឬការប្រកាន់ពូជសាសន៍។ អ្នកធ្វើរឿងនេះបានដោយការដាក់សេចក្តីស្នើ (ញត្តិ) សុំបដិសេធចៅក្រមនោះ។ គំរូសំណើប្តូរចៅក្រមមានបញ្ចូលនៅក្នុងឧបសម្ព័ន្ធ B។

ដើម្បីរកមើលព័ត៌មានអំពីចៅក្រមដែលចាត់ឲ្យកាន់ករណី ឬសំណុំរឿងរបស់អ្នកបាន ឡុកចូលវិបសាយរបស់ OAH តាមតំណបន្ទាប់ [http://www.dgs.ca.gov/oah/GeneralJurisdiction/Calendar.aspx](http://www.dgs.ca.gov/oah/GeneralJurisdiction/Calendar.aspx) (តារាងពេលវេលាផ្តល់សេវាច្បាប់ជាទូទៅ) ហើយវាយបញ្ចូលលេខករណី ឬសំណុំរឿងរបស់អ្នក។ នឹងមានការចាត់ចៅក្រមនៅពេលជិតដល់ថ្ងៃសវនការ។ បន្ទាប់មក ឆ្ពោះទៅកាន់ទំព័រនោះតាមតំណបន្ទាប់ [http://www.dgs.ca.gov/oah/DDSHearings/DDSDecisions.aspx](http://www.dgs.ca.gov/oah/DDSHearings/DDSDecisions.aspx) ហើយវាយបញ្ចូលឈ្មោះចៅក្រម។ អ្នកនឹងពិនិត្យឃើញមានបញ្ជីសំណុំ ឬករណីដែលចៅក្រមបានសម្រេចហើយ។ មើលករណី ឬសំណុំរឿងមួយចំនួនដើម្បីដឹងថាតើនេះគឺពិតជាចៅក្រមដែលអ្នកចង់ឲ្យសម្រេចលើសំណុំរឿង ឬករណីរបស់អ្នកឬអត់។  បើមិនចង់ទេ បន្ទាប់មក ត្រូវដាក់សេចក្តីស្នើ (ញត្តិ) សុំបដិសេធចៅក្រមនោះ។ ផ្ញើ ឬបញ្ជូនតាមទូរសារតាមធម្មតានូវសេចក្តីស្នើ (ញត្តិ) សុំបដិសេធទៅកាន់ OAH។ ផ្តល់ព័ត៌មានទំនាក់ទំនងរបស់អ្នក។ បើអ្នកមិនបានទទួលចម្លើយពី OAH ពេលនោះត្រូវហៅទូរសព្ទទៅ OAH នៅមុនថ្ងៃសវនការ ដើម្បីដឹងថាតើមានការអនុញ្ញាតតាមសំណើអ្នកឬអត់។ តាមធម្មតា ត្រូវមានការអនុញ្ញាតតាមសំណើរបស់អ្នក។

## ជំពូកទី 3 – ការត្រៀមសម្រាប់សវនការ

### ការកំណត់លើហេតុផលផ្នែកច្បាប់របស់អ្នក

ហេតុផលផ្នែកច្បាប់របស់អ្នក គឺច្បាប់ដែលអ្នកកំពុងអាស្រ័យលើដើម្បីបង្ហាញថា អ្នកមានសិទ្ធិទទួលបានអត្ថប្រយោជន៍ ឬសេវាកម្មដែលអ្នក និងមជ្ឈមណ្ឌលតំបន់មិនយល់ស្រប និងអង្គហេតុដែលជួយដល់អំណះអំណាងរបស់អ្នក។ ដើម្បីត្រៀមចំពោះការកំណត់លើហេតុផលផ្នែកច្បាប់របស់អ្នកបាន:

- ពិនិត្យឡើងវិញលើច្បាប់ដែលគាំទ្រជំហររបស់អ្នក។
- ស្វែងរកមើល និងដឹការសម្រេចនៃសវនការយុត្តិធម៌ពីមុនៗតាមតំណបន្ទាប់: http://www.dgs.ca.gov/oah/DDSHearings/DDSDecisions.aspx។

### ការត្រៀមរៀបចំភស្តុតាងរបស់អ្នក

ភស្តុតាងគឺជាការពិតដែលគាំទ្រអំណះអំណាងរបស់អ្នក។ ភស្តុតាងមានជាអាទិ៍ ឯកសារ និងសក្ខីភាពដែលផ្តល់ដោយសាក្សី។ អ្នកគប្បីប្រើតែភស្តុតាងដែលសំខាន់ជាប់ទាក់ទងប៉ុណ្ណោះ។ ភស្តុតាងនឹងសំខាន់ជាប់ទាក់ទង បើវាជួយបង្ហាញឲ្យឃើញច្បាស់ថា អ្នកមានសិទ្ធិទទួលបានអត្ថប្រយោជន៍ ឬសេវាកម្មដែលមជ្ឈមណ្ឌលតំបន់បានបដិសេធ បានព្យាយាមកាត់បន្ថយ ឬបានព្យាយាមដកចេញ។

### ការប្រមូលភស្តុតាងជាលាយលក្ខណ៍អក្សរ (សំណុំឯកសារ)

អ្នកគប្បីប្រមូលភស្តុតាងជាលាយលក្ខណ៍អក្សរមួយចំនួនដែលនឹងជួយដល់ហេតុផលផ្នែកច្បាប់របស់អ្នក។ គំរូភស្តុតាងមួយចំនួន មានជាអាទិ៍:

- បរិយាយអំពីសេវាកម្ម/អត្ថប្រយោជន៍;
- IPP របស់អ្នកដែលបរិយាយអំពីគោលដៅផ្តល់សេវាកម្ម/អត្ថប្រយោជន៍;
- របាយការណ៍ ឬវង្វាយតម្លៃផ្នែកចិត្តសាស្ត្រដែលអ្នកចាំបាច់ត្រូវការសេវាកម្ម/អត្ថប្រយោជន៍;
- ប្រវត្តិរូបសង្ខេបនៃបុគ្គលិកដែលមានការហ្វឹកហ្វឺនឯកទេសត្រឹមត្រូវ;
- របាយការណ៍វិកច្រើនពីអ្នកផ្តល់សេវាកម្ម; និង
- សេចក្តីប្រកាសដែលបានពីបុគ្គលិក ឬអ្នកផ្សេងៗទៀតស្តីពីសេវាកម្ម/អត្ថប្រយោជន៍។

អ្នកអាចស្នើសុំកំណត់ត្រាពីសាលា អ្នកផ្តល់សេវាសុខភាព និងទីភ្នាក់ងាររដ្ឋាភិបាល ដែលអាចនឹងមានព័ត៌មានសំខាន់ៗ។ មិនត្រូវរង់ចាំស្នើសុំកំណត់ត្រា។ ការប្រមូលផ្តុំឯកសារ ជារឿយៗនឹងស៊ីពេលយូរជាងដែលអ្នកបានគិតឃើញ។

ជំនួសឲ្យសំណុំឯកសារដែលមានហើយ អ្នកអាចចាំបាច់ត្រូវការទទួលបានភស្តុតាងឯកសារបន្ថែមទៀត ដើម្បីជួយដោះស្រាយករណី ឬសំណុំរឿងអ្នកបាន (ប្រភេទដូចជា របាយការណ៍រង្វាយតម្លៃរបស់អ្នកជំនាញការ)។ អ្នកអាចសុំឲ្យមនុស្សដែលស្គាល់អ្នកសរសេរលិខិត ឬសេចក្តីប្រកាសនានាបាន។ ចៅក្រមអាចនឹងផ្តល់តម្លៃឲ្យកាន់តែច្រើនទៀតចំពោះព័ត៌មានដែលបានពីបុគ្គលដែលមានវត្តមាននៅអង្គសវនការក្នុងនាមជាសាក្សីម្នាក់ជាងអ្នកដែលជួយសរសេរលិខិត ឬសេចក្តីប្រកាស។

អ្នកមានសិទ្ធិពិនិត្យមើលកំណត់ត្រាមួយចំនួយដែលមាននៅលើឯកសាររបស់មជ្ឈមណ្ឌលតំបន់ដែលមានជាអាទិ៍ សំណុំកំណត់ត្រាដែលមជ្ឈមណ្ឌលតំបន់បានទទួលពីទីភ្នាក់ងារ ឬបុគ្គលខាងក្រៅ។ មជ្ឈមណ្ឌលតំបន់ត្រូវតែផ្តល់ឲ្យអ្នកនូវសិទ្ធិប្រើប្រាស់សំណុំកំណត់ត្រារបស់អ្នកក្នុងរយៈពេលបីថ្ងៃធ្វើការបន្ទាប់ពីអ្នកបានស្នើសុំមើលវា។ បើអ្នកចង់ មជ្ឈមណ្ឌលតំបន់ក៏ត្រូវតែជួយឲ្យអ្នកយល់អំពីកំណត់ត្រារបស់អ្នកដែរ។ បើឯកសារមជ្ឈមណ្ឌលតំបន់មានផ្ទុកនូវឯកសារដែលនឹងជួយបញ្ជាក់ភស្តុតាងចំពោះករណី ឬសំណុំរឿងរបស់អ្នកបាន អ្នកត្រូវបញ្ចូលវានៅក្នុងភស្តុតាងរបស់អ្នក។ មិនត្រូវសន្មត់ថា ALJ នឹងមានវា ពីព្រោះមជ្ឈមណ្ឌលតំបន់មានវារួចហើយ។ ALJ នឹងគ្រាន់តែពិនិត្យមើលភស្តុតាងដែលអ្នក និងមជ្ឈមណ្ឌលតំបន់បានសម្រេចផ្តល់ឲ្យប៉ុណ្ណោះ។

អ្នកគប្បីក្រឡេកមើលគោលការណ៍ទិញសេវាកម្ម (POS) របស់មជ្ឈមណ្ឌលតំបន់។ គោលការណ៍ភាគច្រើនក្នុងចំណោមគោលការណ៍ទាំងនេះ មានបិទប្រកាសនៅលើវិបសាយរបស់មជ្ឈមណ្ឌលតំបន់។ បើអ្នកមិនអាចរកមើលគោលការណ៍ POS នៅលើបណ្តាញ (អនឡាញ) បានទេនោះ ហៅទូរសព្ទទាក់ទងទៅមជ្ឈមណ្ឌលតំបន់ ហើយស្នើសុំមួយច្បាប់។ បើការកំណត់សេវាកម្ម/អត្ថប្រយោជន៍នានាមានសារៈសំខាន់ចំពោះករណី ឬសំណុំរឿងអ្នក ចូរបញ្ចូលវាជាភស្តុតាងរបស់អ្នក។

អ្នកអាចចង់ឲ្យមានលិខិតកោះហៅទីភ្នាក់ងារមួយឲ្យបង្កើតសំណុំកំណត់ត្រាសម្រាប់សវនការរបស់អ្នក។ លិខិត/ដីកាកោះហៅឲ្យចូលខ្លួន បង្ខិតបង្ខំឲ្យទីភ្នាក់ងារមួយនាំមកជាប់ខ្លួននូវសំណុំកំណត់ត្រាដែលពួកគេមាន និងដើម្បីពិនិត្យផ្ទៀងផ្ទាត់ប្រាប់ទៅកាន់តុលាការថា សំណុំឯកសារ ឬកំណត់ត្រាទាំងនោះមិនទាន់មានការផ្លាស់ប្តូរនៅឡើយទេ។ អ្នកអាចស្នើសុំឲ្យទីភ្នាក់ងារធ្វើកិច្ចការនេះបានទាំងតាមរយៈសេចក្តីប្រកាស ទាំងតាមរយៈសក្ខីភាពផ្ទាល់បាន។ គេអាចរកឃើញទម្រង់បែបបទដីកា ឬលិខិតកោះហៅសម្រាប់សវនការយុត្តិធម៌របស់មជ្ឈមណ្ឌលតំបន់តាមតំណបន្ទាប់: http://www.documents.dgs.ca.gov/oah/forms/oah1-subpoena.pdf#search=subpoena%20Form&view=FitH&pagemode=none។

## ការត្រៀមរៀបចំសាក្សី

សក្ខីភាពរបស់សាក្សី ក៏ជាប្រភេទភស្តុតាងដែរ។ ជួនកាល សាក្សីចាំបាច់ត្រូវការឲ្យមានដីកា ឬលិខិតកោះហៅ។ ដីកា ឬលិខិតកោះហៅ គឺជាលិខិតបញ្ជាផ្លូវការមួយប្រភេទដែលដែលបង្ខិតបង្ខំឲ្យពួកគេចូលខ្លួនមកក្នុងអង្គសវនាការដើម្បីធ្វើកស្សិណសាក្សី ឬផ្តល់សក្ខីកម្ម។ អ្នកត្រូវកោះហៅសាក្សី និងស្នើឲ្យសាក្សីផ្តល់សក្ខីកម្មឲ្យបានឆាប់ៗនៅពេលដែលអ្នកមានកំណត់ថ្ងៃសវនាការហើយ ដើម្បីឲ្យអ្នកទាំងនេះត្រូវមានវត្តមាន។ គេអាចរកឃើញទម្រង់បែបបទដីកា ឬលិខិតកោះហៅតាមតំណបន្ទាប់នេះ http://www.documents.dgs.ca.gov/oah/forms/oah1-subpoena.pdf#search=Subpoena%20Form&view=FitH&pagemode=none។

អ្នកត្រូវសរសេរសំណួរឲ្យសាក្សីរបស់អ្នកទុកជាមុន។ ពិនិត្យមើលលើសំណួរទាំងនេះជាមួយនឹងសាក្សី ដើម្បីធ្វើឲ្យប្រាកដថា សាក្សីបានយល់នូវអ្វីដែលអ្នកនឹងសាកសួរ និងថាចម្លើយនោះមានសារៈសំខាន់ចំពោះករណី ឬសំណុំរឿងរបស់អ្នក។ បើចម្លើយរបស់សាក្សីមិនជួយអ្នកបាន ពេលនោះមិនត្រូវសាកសួរសំណួរនៅឯសវនាការឡើយ។ គេត្រូវចេះប្រើពាក្យសម្រាប់ការផ្លាស់ប្តូរវិធីសួរសំណួរដែលអាចនឹងជួយបានច្រើន។

លើសពីនេះ អ្នកត្រូវត្រៀមរៀបចំផ្តល់សក្ខីកម្ម ដោយសារអ្នកគឺជាសាក្សីដ៏ល្អបំផុតសម្រាប់អ្នកខ្លួនឯង ឬកូនរបស់អ្នក។ ត្រូវមានការត្រៀមនិយាយអំពីមូលហេតុដែលអ្នកចាំបាច់ត្រូវការសេវាកម្ម/អត្ថប្រយោជន៍។ អ្នកអាចនឹងចង់និយាយអំពីមូលហេតុដែលការទទួលបានសេវាកម្ម/អត្ថប្រយោជន៍ផ្សេងៗទៀតមិនបានសម្រេចជាស្ថាពរនៅឡើយ។ បញ្ហាទាំងនេះអាចជាឧទាហរណ៍សំខាន់ៗនៃមូលហេតុដែលអ្នកចាំបាច់ត្រូវការសេវាកម្ម/អត្ថប្រយោជន៍ដែលអ្នកបានស្នើសុំ។

## ការផ្លាស់ប្តូរគ្នានូវបញ្ជីឈ្មោះសាក្សី និងសេចក្តីថ្លែងទៅវិញទៅមក

រយៈពេលយ៉ាងតិច 5 ថ្ងៃមុនសវនាការ អ្នក និងមជ្ឈមណ្ឌលតំបន់ត្រូវតែផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវបញ្ជីឈ្មោះសាក្សី និងសំណៅឯកសារដែលអាចផ្ញើទៅបានដែលអ្នកអាចប្រើជាភស្តុតាងនៅឯសវនាការ។ នោះមានន័យថា អ្នក និងមជ្ឈមណ្ឌលតំបន់ត្រូវតែទទួលបាននូវសំណុំឯកសារ និងបញ្ជីឈ្មោះក្នុងរយៈពេល 5 ថ្ងៃ នៅមុនសវនាការ។ បញ្ជីឈ្មោះសាក្សីត្រូវតែមានប្រកាសសង្ខេបមួយដែលប្រាប់ងមពីអ្វីដែលសាក្សីម្នាក់ៗត្រូវផ្តល់សក្ខីកម្ម។ គំរូបញ្ជីឈ្មោះសាក្សី និងសេចក្តីថ្លែងមានបញ្ចូលក្នុងឧបសម្ព័ន្ធ C។ ALJ អាចទប់អ្នក ឬមជ្ឈមណ្ឌលតំបន់ពីការណែនាំប្រាប់អំពីឯកសារ និងសាក្សីដែលមិនទាន់មានការផ្តល់ឲ្យគ្នាទៅវិញទៅមកក្នុងរយៈពេល 5 ថ្ងៃតាមប្រតិទិននៅមុនអង្គសវនាការ។

## ជំពូកទី 4 – កំឡុងពេល និងក្រោយសវនការ

ត្រូវមកដល់កន្លែងសវនការឲ្យបានមុនពេលចាប់ផ្តើមយូរបន្តិច។ សវនការអាចជាដំណើរការដ៏យូរមួយបាន ដូច្នេះអ្នកអាចចង់ដាក់ទឹក និងអាហារសម្រន់មកជាមួយ។ ដាក់មកជាប់ខ្លួននូវប៊ិច និងក្រដាសដើម្បីកត់កំណត់ហេតុនៅកំឡុងពេលសវនការ។

### <u>សេចក្តីថ្លែងបើក</u>

អ្នកត្រូវផ្តល់នូវសេចក្តីថ្លែងបើកមួយ។ សេចក្តីថ្លែងបើកមួយមិនចាំបាច់មានទេ តែវានឹងជួយពន្យល់ប្រាប់ដល់ ALJ នូវអ្វីដែលអង្គសវនការកំពុងនិយាយដល់។ សេចក្តីថ្លែងបើករបស់អ្នក ត្រូវបរិយាយអំពីសេវាកម្ម/អត្ថប្រយោជន៍ដែលអ្នកកំពុងតែស្នើសុំ និងមូលហេតុនៃតម្រូវការ។ វាត្រូវមានបញ្ចូលនូវច្បាប់ដែលគាំទ្រសំណើរបស់អ្នក។ ត្រូវឲ្យប្រាកដប្រជាចំពោះការបរិយាយអំពីអ្នកខ្លួន ដើម្បីឲ្យ ALJ បានយល់នូវអ្វីដែលអ្នក ឬកូនអ្នកចាំបាច់ត្រូវការ។ សេចក្តីថ្លែងបើករបស់អ្នក គឺជាសេចក្តីសង្ខេបខ្លីមួយអំពីករណី ឬសំណុំរឿងរបស់អ្នក។ មជ្ឈមណ្ឌលតំបន់ ត្រូវអានសេចក្តីថ្លែងបើករបស់ខ្លួនជាមុន។ បន្ទាប់មក ទើបអ្នកត្រូវអានរបស់អ្នក។

### <u>ការសួរចម្លើយសាក្សី</u>

*សាក្សីរបស់មជ្ឈមណ្ឌលតំបន់*

មជ្ឈមណ្ឌលតំបន់ ត្រូវបង្ហាញសាក្សីរបស់ខ្លួនជាមុន។ អ្នកអាចសាកសួរចម្លើយពីសាក្សីរបស់មជ្ឈមណ្ឌលតំបន់បាន ក្រោយពេលមានការសាកសួរសំណួរទៅមជ្ឈមណ្ឌលតំបន់ហើយ។ នេះគេហៅថា៖ "ការត្រួតពិនិត្យ"។ សំណួររបស់អ្នកត្រូវជួយបង្ហាញឲ្យច្បាស់ថា សាក្សីមិនយល់មួយ ឬមិនចាំអង្គហេតុពិតប្រាកដ។ លើសពីនេះ អ្នកអាចសួរសំណួរដែលបង្ហាញថា សាក្សីម្នាក់កំពុងតែកាន់ជើងម្ខាងៗ ដោយការផ្លាស់ប្តូរនូវអ្វីដែលគេបាននិយាយពីមុនមក ឬអាចនឹងមិនធ្វើការប្រាប់ការពិត។

ត្រូវផ្ចង់ស្មារតីឲ្យបានខ្ពស់ នៅខណៈពេលដែលសាក្សីរបស់មជ្ឈមណ្ឌលតំបន់កំពុងផ្តល់សក្ខីកម្ម។ អ្នកអាចនឹងកត់សម្គាល់ឃើញចំណុចខ្សោយដែលនឹងបង្ហាញឲ្យឃើញច្បាស់ពេលក្រោយមកទៀត នៅកំឡុងពេលមានការត្រួតពិនិត្យរបស់អ្នក។ ផ្សេងពីនេះ អ្នកត្រូវជជីកសួរសំណួរសម្រាប់ការត្រួតពិនិត្យដែលអ្នកបានសរសេរនៅមុនពេលសវនការ។ ការសួរសំណួរមួយមិនមែនជាគំនិតល្អនោះទេ បើអ្នកមិនទាន់បានដឹងចម្លើយ ក្នុងករណីដែលអ្នកមិនគិតថា ចម្លើយពិតនឹងជួយគាំទ្រដល់ហេតុផលរបស់អ្នកបានយ៉ាងច្រើននោះ។

*សាក្សីផ្ទាល់ខ្លួនរបស់អ្នក*

បន្ទាប់មក អ្នកត្រូវសាកសួរសំណួរសាក្សីផ្ទាល់ខ្លួនរបស់អ្នក។ នេះគេហៅថា៖ “ការត្រួតពិនិត្យដោយផ្ទាល់”។ សាក្សីនានា គប្បីនិយាយតែអំពីរឿងរ៉ាវដែលពួកគេបានធ្វើ ឬបានឃើញ ឬបានឮដោយពួកគេខ្លួនឯង។ អ្នកត្រូវសួរសំណួរខ្លីៗ សាមញ្ញៗ និងច្បាស់លាស់។

ជាកិច្ចបន្ថែមទៅនឹងការបង្ហាញហេតុផលសំខាន់ៗរបស់អ្នក អ្នកអាចសួរសំណួរសាក្សីដែលនឹងមិនត្រូវរឿងដែលសាក្សីរបស់មជ្ឈមណ្ឌលតំបន់អាចបាននិយាយហើយ។ ផ្សេងពីនេះ អ្នកត្រូវជជីកសួរសំណួរដែលអ្នកបានត្រៀមទុកនៅមុនពេលសវនការ។ អ្នកអាចសួរសំណួរតាមដានបាន បើចម្លើយរបស់សាក្សីអ្នកមិនច្បាស់លាស់។

មជ្ឈមណ្ឌលតំបន់ត្រូវមានឱកាសពិនិត្យមើលលើសាក្សីរបស់អ្នក។ រីឯ ALJ ក៏អាចសួរសំណួរសាក្សីបានដែរ។ ក្រោយពេលដែលមជ្ឈមណ្ឌលតំបន់បានពិនិត្យមើលលើសាក្សីរបស់អ្នកហើយ អ្នកត្រូវមានឱកាសសួរសំណួរសាក្សីរបស់អ្នកច្រើនទៀតបានដែរ។ នេះគេហៅថា៖ “ការត្រួតពិនិត្យបកវិញ”។ ស្ថិតត្រង់ចំណុចនេះ អ្នកអាចឲ្យសាក្សីអ្នកបកស្រាយ ឬរៀបពាក្យ ឬថាឡើងវិញនូវអ្វីដែលអវិជ្ជមានដែលអាចនឹងកើតឡើងហើយនៅកំឡុងពេលនៃការត្រួតពិនិត្យ។

**<u>សេចក្តីថ្លែងបិទ/សេចក្តីសង្ខេបបិទជាលាយលក្ខណ៍អក្សរ</u>**

នៅពេលដែលអ្នកបានតស៊ូគ្រប់មធ្យោបាយក្នុងអង្គសវនការហើយ អ្នកនឹងដឹងថា ចៅក្រមមិនទាន់បានជ្រាបគ្រប់ជ្រុងជ្រោយដែលត្រូវធ្វើការសម្រេចត្រឹមត្រូវមួយបាន។ បើដូច្នោះមែន អ្នកអាចនឹងស្នើឲ្យចៅក្រម “រក្សាទុកកំណត់ត្រាឲ្យនៅចំហ” បាន។ ចៅក្រមអាចនឹងនិយាយថា៖ “បាទ/ចាស” ឬ “ទេ” ចំពោះសំណើនេះ។ បើចៅក្រមឯកភាពឲ្យរក្សាទុកកំណត់ត្រានៅចំហ វានឹងអនុញ្ញាតឲ្យភាគីទាំងសង្ខាងផ្តល់ឲ្យចៅក្រមនូវឯកសារ និងព័ត៌មានច្រើនទៀតក្រោយរយៈពេលនៃអង្គសវនការ។

តាមធម្មតា ALJ ត្រូវស្នើឲ្យមានសេចក្តីថ្លែងបិទមួយនៅចុងបញ្ចប់នៃអង្គសវនការដើម្បីបូកសរុបភស្តុតាងបាន។ នេះគឺជាពេលដ៏ល្អមួយដែលត្រូវប៉ះប៉ូវនូវអ្វីដែលអ្នកបង្ហាញឲ្យឃើញនៅឯសវនការ និងបន្តនិយាយអំពីជំហររបស់អ្នកដែលអ្នកត្រូវមានសិទ្ធិទទួលបានសេវាកម្ម/អត្ថប្រយោជន៍។ ជួនកាល ភាគីទាំងសង្ខាងឯកភាពគ្នាធ្វើសេចក្តីសង្ខេបបិទជាលាយលក្ខណ៍អក្សរមួយជំនួសឲ្យសេចក្តីសង្ខេបបិទផ្ទាល់មាត់។ ជម្រើសនេះបើកឲ្យអ្នកគិតអំពីសក្ខីភាពទាំងអស់ដែលអ្នកបានបូកសរុបហេតុផលរបស់អ្នក។ សេចក្តីសង្ខេបបិទជាលាយលក្ខណ៍អក្សរមួយ ត្រូវមានផ្តល់នូវព័ត៌មាន និងអង្គហេតុនានាដែលអ្នកបានបង្ហាញ និងដាក់ចេញនូវច្បាប់ដែលនឹងជួយដល់ករណី ឬសំណុំរឿងរបស់អ្នក។ បើ ALJ បានរក្សាទុកកំណត់ត្រាឲ្យនៅចំហ

បន្ទាប់ពីសវនការ ហើយបានអនុញ្ញាតឲ្យមានការបង្ហាញភស្តុតាងច្រើនទៀត អ្នកអាចនឹងបូកបញ្ចូលវាទៅក្នុងសេចក្តីសង្ខេបបិទរបស់អ្នកបាន។ គំរូសេចក្តីសង្ខេបបិទ មានការបញ្ចូលនៅក្នុងឧបសម្ព័ន្ធ D។

**ក្រោយសវនការ**

ក្រោយរយៈពេលនៃសវនការរបស់អ្នក ALJ មានពេល 10 ថ្ងៃដើម្បីសរសេរសេចក្តីសម្រេចមួយបាន។ សេចក្តីសម្រេចនេះ ត្រូវតែមានការធ្វើឡើងក្នុងរយៈពេលដែលមិនលើសពី 80 ថ្ងៃ បន្ទាប់ពីអ្នកបានស្នើឲ្យមានការប្តឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) ហើយ។ គំរូសេចក្តីសម្រេច មានបញ្ចូលក្នុងឧបសម្ព័ន្ធ E។ សេចក្តីសម្រេចរបស់ ALJ ត្រូវតែ:

- មានការសរសេរឡើងយ៉ាងសាមញ្ញដែលជាភាសាប្រើប្រចាំថ្ងៃ
- បញ្ចូលសង្ខេបអង្គហេតុ
- បញ្ចូលសេចក្តីថ្លែងអំពីភស្តុតាងដែល ALJ បានប្រើធ្វើសេចក្តីសម្រេច
- បញ្ចូលសេចក្តីសម្រេចនូវគ្រប់ៗបញ្ហា ឬសំណួរដែលមាននៅក្នុងសំណើសវនការ និងមានការបង្ហាញប្រាប់នៅកំឡុងពេលនៃអង្គសវនការ និង
- លើកឡើងអំពីច្បាប់ បញ្ញត្តិច្បាប់ និងគោលការណ៍ដែលជួយដល់សេចក្តីសម្រេចរបស់ ALJ។

បើអ្នកជំទាស់នឹងសេចក្តីសម្រេចនៃអង្គសវនការ អ្នកមានសិទ្ធិប្តឹងសាទុក្ខ ឬតវ៉ាទៅតុលាការជាន់ខ្ពស់បាន។ អ្នកត្រូវតែប្តឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) ក្នុងរយៈពេល 90 ថ្ងៃ ក្រោយពេលដែលអ្នកបានទទួលសេចក្តីសម្រេចនៃអង្គសវនការហើយ។ សម្រាប់ព័ត៌មានបន្ថែមអំពីដំណើរការនេះ មើលផ្នែកស្តីពី <u>សិទ្ធិដែលស្ថិតក្រោមច្បាប់ Lanterman</u> (ជំពូកទី 12): http://www.disabilityrightsca.org/pubs/506301Ch12.pdf

**ផ្នែកទី 2: <u>ឧបសម្ព័ន្ធ</u>**

## ឧបសម្ព័ន្ធ A: គំនូសតាងនៃចរន្តកាលវិភាគសម្រាប់សវនការយុត្តិធម៌

**ត្រូវស្នើឲ្យមានសវនការយុត្តិធម៌មួយ ក្នុងករណីដែល:** (1) មជ្ឈមណ្ឌលតំបន់សម្រេច (ដោយគ្មានការយល់ព្រមរបស់អ្នក) កាត់ កាត់បន្ថយ ឬផ្លាស់ប្តូរសេវាកម្ម/អត្ថប្រយោជន៍ ឬជំនួយនៅក្នុង IPP របស់អ្នក; (2) អ្នកស្នើសុំសេវាកម្ម/អត្ថប្រយោជន៍ ឬជំនួយ ហើយមជ្ឈមណ្ឌលតំបន់បដិសេធសំណើអ្នក; (3) អ្នកទទួលបានការជូនដំណឹងមកថា អ្នកមិនមានសិទ្ធិ ឬលែងមានសិទ្ធិទទួលបានសេវាកម្ម/អត្ថប្រយោជន៍ពីមជ្ឈមណ្ឌលតំបន់តទៅទៀតហើយ។

**សំណួរទី 1: តើបច្ចុប្បន្ន អ្នកកំពុងទទួលបានសេវាកម្ម/អត្ថប្រយោជន៍ ឬជំនួយដែលមជ្ឈមណ្ឌលតំបន់ចង់កាត់ កាត់បន្ថយ ឬផ្លាស់ប្តូរឬ?**

បាទ/ចាស > ដាក់សំណើអ្នក ដើម្បីសុំឲ្យមានសវនការក្នុងរយៈពេល 10 ថ្ងៃចាប់ពីពេលដែលអ្នកបានទទួលសេចក្តីជូនដំណឹងហើយៗ សេវាកម្ម/អត្ថប្រយោជន៍នឹងបន្តមានរហូតដល់មានសេចក្តីសម្រេចចុងក្រោយ។ ឆ្ពោះទៅកាន់សំណួរទី 2:

ទេ > អ្នកត្រូវតែដាក់សំណើអ្នក ដើម្បីសុំឲ្យមានសវនការក្នុងរយៈពេល 30 ថ្ងៃនៅបន្ទាប់ពីមានការជូនដំណឹងដោយមជ្ឈមណ្ឌលតំបន់។ ឆ្ពោះទៅកាន់សំណួរទី 2:

**សំណួរទី 2: តើអ្នកចង់ឲ្យមានជម្រើសកិច្ចប្រជុំក្រៅផ្លូវការឬទេ?**

បាទ/ចាស > កិច្ចប្រជុំក្រៅផ្លូវការមួយ ត្រូវតែមានការប្រារព្ធធ្វើឡើងក្នុងរយៈពេល 10 ថ្ងៃក្រោយមានបង្កាន់ដៃទទួលសំណើឲ្យមានសវនការរបស់មជ្ឈមណ្ឌលតំបន់ បើអ្នកមិនឯកភាពឲ្យមានការពន្យាពេលយូរតទៅទៀតបាន។

អ្នកត្រូវតែទទួលបានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ (ដីកាសម្រេច) ពីមជ្ឈមណ្ឌលតំបន់ក្នុងរយៈពេល 5 ថ្ងៃបន្ទាប់ពីកិច្ចប្រជុំក្រៅផ្លូវការ។ ឆ្ពោះទៅកាន់សំណួរទី 3:

ទេ > ឆ្ពោះទៅកាន់សំណួរទី 4 ដែលយោងតាមជម្រើសនៃការសម្រុះសម្រួល។

**សំណួរទី 3: តើអ្នកមានការពេញចិត្តនឹងសេចក្តីសម្រេចរបស់មជ្ឈមណ្ឌលតំបន់ដែរឬទេ?**

បាទ/ចាស > ប្រាប់ទៅមជ្ឈមណ្ឌលតំបន់ថា អ្នកដកសំណើសុំឲ្យមានសវនការយុត្តិធម៌របស់អ្នកហើយ។ សេវាកម្ម/អត្ថប្រយោជន៍ដែលមានការឯកភាពផ្តល់ឲ្យនៅក្នុងសេចក្តីសម្រេចនៃកិច្ចប្រជុំក្រៅផ្លូវការរបស់អ្នក នឹងចាប់ផ្តើមមានក្នុងរយៈពេល 10 ថ្ងៃក្រោយការទទួលបានសំណើសុំដករបស់អ្នក។ បន្តទៅមុខទៀត

ទេ > ឆ្ពោះទៅកាន់សំណួរទី 4 ដែលយោងតាមជម្រើសនៃការសម្រុះសម្រួល។

**សំណួរទី 4: តើអ្នកចង់ឲ្យមានជម្រើសនៃការសម្រុះសម្រួលឬទេ?**

បាទ/ចាស > តើមជ្ឈមណ្ឌលតំបន់យល់ព្រមទទួលយកការសម្រុះសម្រួលឬទេ? ពួកគេត្រូវតែយល់ព្រមទទួលយកការសម្រុះសម្រួលក្នុងរយៈពេល 5 ថ្ងៃ។

បើមជ្ឈមណ្ឌលតំបន់យល់ព្រមទទួលយក ការសម្រុះសម្រួលត្រូវតែមានការប្រព្រឹត្តទៅក្នុងរយៈពេល 30 ថ្ងៃក្រោយមានបង្កាន់ដៃទទួលសំណើឲ្យមានសវនការរបស់មជ្ឈមណ្ឌលតំបន់ បើអ្នកមិនឯកភាពឲ្យមានការពន្យាពេលយូរតទៅទៀតបាន។ ឆ្ពោះទៅកាន់សំណួរទី 5:

បើមជ្ឈមណ្ឌលតំបន់ មិនយល់ព្រមទទួលយកការសម្រុះសម្រួលក្នុងរយៈពេល 5 ថ្ងៃ ករណី ឬសំណុំរឿងរបស់អ្នកត្រូវបន្តនីតិវិធីទៅសវនការយុត្តិធម៌។ ឆ្ពោះទៅកាន់សំណួរទី 6:

ទេ > អ្នកអាចបន្តនីតិវិធីទៅសវនការយុត្តិធម៌មួយបាន។ ឆ្ពោះទៅកាន់សំណួរទី 6:

**សំណួរទី 5: តើអ្នកបានឈានដល់កិច្ចព្រមព្រៀងមួយនៅក្នុងការសម្រុះសម្រួលឬទេ?**

បាទ/ចាស > ប្រាប់ទៅមជ្ឈមណ្ឌលតំបន់ថា អ្នកដកសំណើសុំឲ្យមានសវនការយុត្តិធម៌របស់អ្នកហើយ។ សេវាកម្ម/អត្ថប្រយោជន៍ដែលមានការឯកភាពផ្តល់ឲ្យនៅក្នុងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់អ្នក នឹងចាប់ផ្តើមមានក្នុងរយៈពេល 10 ថ្ងៃក្រោយការទទួលបានសំណើសុំដករបស់អ្នក។ បន្តទៅមុខទៀត

ទេ > អ្នកអាចបន្តនីតិវិធីទៅសវនការយុត្តិធម៌មួយបាន។ ឆ្ពោះទៅកាន់សំណួរទី 6:

**សំណួរទី 6: តើអ្នកចង់បន្តនីតិវិធីជាមួយនឹងសវនការយុត្តិធម៌ឬទេ?**

បាទ/ចាស > សវនការយុត្តិធម៌មួយ នឹងមានការប្រព្រឹត្តទៅក្នុងរយៈពេល 50 ថ្ងៃក្រោយមានបង្កាន់ដៃទទួលសំណើឲ្យមានសវនការរបស់មជ្ឈមណ្ឌលតំបន់ បើចៅក្រមមិនអនុញ្ញាតឲ្យមានការពន្យាពេលយូរតទៅទៀតបាន ដោយសារមានមូលហេតុត្រឹមត្រូវ។

សេចក្តីសម្រេចនៃសវនការយុត្តិធម៌ ត្រូវតែមានការចេញឲ្យក្នុងរយៈពេល 10 ថ្ងៃធ្វើការបន្ទាប់ថ្ងៃចុងក្រោយនៃសវនការ និងមិនលើសពី 80 ថ្ងៃក្រោយការដាក់សំណើ

សុំឲ្យមានសវនការដំបូងរបស់អ្នក បើអ្នកបានបដិសេធបន្ទាត់ពេលវេលាតាមរយៈការស្នើសុំឲ្យមានរយៈពេលនៃការបន្ត (ការលើកទៅពេលក្រោយ)។

បើសេវាកម្ម/អត្ថប្រយោជន៍ស្ថិតក្រោមការផ្គត់ផ្គង់ថវិការបស់កម្មវិធី Medi-Cal Home និង Community Based Waiver ពេលនោះ សេចក្តីសម្រេចនេះនឹងមានការពិនិត្យឡើងវិញដោយ DHCS ក្នុងរយៈពេល 90 ថ្ងៃក្រោយការទទួលបានសំណើឲ្យមានសវនការ។ អាចនឹងមានការអនុម័ត បដិសេធ ឬសរសេរសេចក្តីសម្រេចនេះខុសៗគ្នា។ ឆ្ពោះទៅកាន់សំណួរទី 7:

ទេ > អ្នកអាចនឹងដកខ្លួនពីសវនការយុត្តិធម៌តាមរយៈការទាក់ទង OAH។

**សំណួរទី 7: តើអ្នកមានការពេញចិត្តនឹងសេចក្តីសម្រេចសវនការយុត្តិធម៌ដែរឬទេ?**

បាទ/ចាស > សេវាកម្ម/អត្ថប្រយោជន៍ និងជំនួយ នឹងមានការផ្តល់ឲ្យដូចដែលមាននៅក្នុងសេចក្តីសម្រេចនៃអង្គសវនការយុត្តិធម៌។

ទេ > អ្នកមានពេល 90 ថ្ងៃដើម្បីដាក់សេចក្តីស្នើ (ញត្តិ) ឲ្យតុលាការជាន់ខ្ពស់ពិនិត្យឡើងវិញ និងបដិសេធដីកាសម្រេចរបស់ចៅក្រមច្បាប់រដ្ឋបាល។ អ្នកអាចទាក់ទងទៅគ្រោងការណ៍ការពារ & គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ា ឬមេធាវីឯកជនដើម្បីសុំជំនួយបាន។

ចំណាំ: មជ្ឈមណ្ឌលតំបន់អាចនឹងបន្តនីតិវិធីកាត់ ឬកាត់បន្ថយសេវាកម្ម/អត្ថប្រយោជន៍ក្នុងរយៈពេល 10 ថ្ងៃបាន បើមេធាវីអ្នកមិនទាន់បានទទួលដីកាតុលាការឲ្យបន្តផ្តល់សេវាកម្ម/អត្ថប្រយោជន៍នៅខណៈពេលដែលតុលាការកំពុងសម្រេចលើការប្តឹងសាទុក្ខ ឬឧទ្ធរណ៍ (តវ៉ា) របស់អ្នក។

**<u>ឧបសម្ព័ន្ធ B: គំរូសំណើសុំផ្លាស់ប្តូរចៅក្រម</u>**

តាមទូរសារ (213) 555-5555

23 កញ្ញា 2015

Susan Formaker

Presiding Administrative Law Judge

Office of Administrative Hearings

320 W. Fourth Street, Suite 630

Los Angeles, CA 90013

យោង: ការយល់ទាស់របស់ចុងចោទ ឬមេធាវីចំពោះសំណើគ្មានហេតុផលនៃក្រុមប្រឹក្សាតុលាការ

John Doe v Regional Center

OAH No. 201511100000

កាលបរិច្ឆេទនៃសវនការ: 28 កញ្ញា 2015

លោកចៅក្រម Formaker ជាទីគោរពរាប់អាន!

ខ្ញុំបាទកំពុងសរសេរជួសមុខឲ្យ John Doe ដែលស្នើសុំឲ្យមានការចាត់ចៅក្រមផ្សេងទៀតសម្រាប់សវនការរបស់គាត់នៅថ្ងៃទី 28 ខែកញ្ញាឆ្នាំ 2015។ ចៅក្រមដែលចាត់មកបច្ចុប្បន្ននេះ គឺ Sarah Smith។ យើងខ្ញុំសូមស្នើឲ្យមានការប្តូរនេះដោយយោងតាមចំណងជើងទី 1 នៃក្រមច្បាប់រដ្ឋកាលីហ្វ័រញ៉ា ត្រង់ផ្នែកទី 1034 និងផ្នែកតី 11425.40 នៃក្រមច្បាប់រដ្ឋាភិបាល។ សូមភ្ជាប់មកជាមួយនូវសេចក្តីប្រកាសដែលមានចែងបញ្ញត្តិដែលចាំបាច់ត្រូវក្នុងផ្នែកនោះ។

សូមអរគុណច្រើនចំពោះសម្មានការរបស់លោក។ សូមមេត្តាកុំស្ទាក់ស្ទើរទាក់ទងមកខ្ញុំបាទតាមទូរសព្ទដែលមានលេខ (213) 555-5555 ក្នុងករណីចាំបាច់។

សូមលោក មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។

Jane Doe

ឯកសារភ្ជាប់

សេចក្តីថ្លែងរបស់ Jane Doe

មាតារបស់ John Doe

ខ្ញុំ (Jane Doe) សូមប្រកាសថា:

1) ខ្ញុំគឺជាមាតាបិតាដែលតំណាងឲ្យភាគីមួយដែលមានបញ្ហាមិនទាន់បានដោះស្រាយ។

2) ចៅក្រមដែលចាត់ឲ្យមកអង្គសវនការនេះ មានការប្រកាន់ពូជសាសន៍ប្រឆាំងនឹងផលប្រយោជន៍នៃភាគីនេះដែលដូច្នេះហើយទើបអ្នកប្រកាសនេះជឿជាក់ថាកូនប្រុសរបស់គាត់មិនអាចមានសវនការយុត្តិធម៌ និងមិនលម្អៀងបាននៅចំពោះមុខចៅក្រម Sarah Smith។

ប្រកាសនេះស្ថិតក្រោមច្បាប់នៃរដ្ឋកាលីហ្វ័រញ៉ាស្តីពីទោសទណ្ឌនៃការភូតភរ និងមានការចុះហត្ថលេខានៅថ្ងៃទី 23 ខែកញ្ញា ឆ្នាំ 2015 នៅទីក្រុងឡូសអង់ជេឡេសនៃរដ្ឋកាលីហ្វ័រញ៉ា។

សូមលោក មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។

______________________________

Jane Doe

**ឧបសម្ព័ន្ធ C: គំរូបញ្ជីឈ្មោះសាក្សី និងឯកសារភស្តុតាងរបស់អ្នកប្តឹងតវ៉ា**

ឈ្មោះអ្នក

ឈ្មោះ និងលេខផ្លូវនៃអាសយដ្ឋានរបស់អ្នក

ទីក្រុង, រដ្ឋ, និងហ្ស៊ីពកូដរបស់អ្នក

លេខទូរសព្ទដៃអ្នក

តំណាងដែលទទួលបានការអនុញ្ញាតរបស់ [Name of Regional Center Client]

ការិយាល័យទទួលបន្ទុកសវនាការផ្លូវការ

រដ្ឋកាលីហ្វ័រញ៉ា

ដោយយោងតាម:

ឈ្មោះអ្នកប្តឹងតវ៉ា,

អ្នកប្តឹងតវ៉ា,

និង

មជ្ឈមណ្ឌលតំបន់,

ទីភ្នាក់ងារសេវាកម្ម

ករណី/សំណុំរឿងលេខ:

កាលបរិច្ឆេទនៃសវនការ:

ម៉ោងសវនការ:

ទីកន្លែងសវនការ:

ចៅក្រមច្បាប់រដ្ឋបាល:

បញ្ជីឈ្មោះសាក្សី និងឯកសារភស្តុតាងរបស់អ្នកប្តឹងតវ៉ា

## បញ្ជីឈ្មោះសាក្សី

1) Witness First Name Last Name នឹងផ្តល់សក្ខីកម្មអំពី [describe what they will testify about.]

2) Witness First Name Last Name កំពុងស្ថិតក្រោមការកោះហៅឲ្យផ្តល់សក្ខីកម្មអំពី [describe what they will testify about.]

3) គំរូ First Name Last Name: Mr. Last Name នឹងផ្តល់សក្ខីកម្មអំពីកម្មវិធីការចម្រើនខ្លួន, គោលដៅ, និងតម្រូវការសេវាកម្ម/អត្ថប្រយោជន៍របស់អ្នកប្តឹងតវ៉ា។

## បញ្ជីឯកសារភស្តុតាង

1) សេចក្តីសង្ខេបបើក

2) ឯកសារបញ្ជាក់សវនការ
   a. សំណើសុំសេវាកម្ម/អត្ថប្រយោជន៍ដែលចុះកាលបរិច្ឆេទ [Insert Date]
   b. លិខិតបដិសេធដែលចុះកាលបរិច្ឆេទ [Insert Date]
   c. សំណើឲ្យមានសវនការដែលចុះកាលបរិច្ឆេទ [Insert Date]
   d. ការជូនដំណឹងអំពីសវនការ

3) ព័ត៌មានអំពីកម្មវិធី

4) ប្រវត្តិរូបសង្ខេបរបស់បុគ្គលិកកម្មវិធី

5) របាយការណ៍រីកចម្រើនពី [Insert name of program] ដែលចុះកាលបរិច្ឆេទ [Insert Date]

6) របាយការណ៍រីកចម្រើនពី [Insert name of program] ដែលចុះកាលបរិច្ឆេទ [Insert Date]

7) របាយការណ៍ការវាយតម្លៃផ្នែកចិត្តវិទ្យារបស់ [Insert name of Assessor] ដែលចុះកាលបរិច្ឆេទ [Insert Date]

8) IPP ដែលចុះកាលបរិច្ឆេទ [Insert Date]

9) សេចក្តីប្រកាសរបស់ [Insert Name] ដែលចុះកាលបរិច្ឆេទ [Insert Date]

10) ផ្នែកនានានៃច្បាប់ Lanterman សម្រាប់ប្រកាសរបស់ថៅក្រម

**ឧបសម្ព័ន្ធ D: គំរូសេចក្ដីសង្ខេបបិទរបស់អ្នកប្ដឹងតវ៉ា**

Bill X

ឈ្មោះ និងលេខផ្លូវនៃអាសយដ្ឋាន

ទីក្រុង, រដ្ឋ, ហ្ស៊ីពកូដ

លេខទូរសព្ទ

Bill X ដែលជាឪពុក និងជួសមុខឲ្យអ្នកប្ដឹងតវ៉ា (អានីតិជន)

**ការិយាល័យសវនការផ្លូវការនៃរដ្ឋកាលីហ្វ័រញ៉ា**

ដោយយោងតាម: ករណី/សំណុំរឿង # 2015000000

SALLY X, សេចក្ដីសង្ខេបនៃអង្គសវនការរបស់អ្នកប្ដឹងតវ៉ា

អ្នកប្ដឹងតវ៉ា

ប្រឆាំងនឹង

មជ្ឈមណ្ឌលតំបន់,

ទីភ្នាក់ងារសេវាកម្ម

កាលបរិច្ឆេទ: 2015-09-12

ម៉ោង: ម៉ោង 10:00 ល្ងាច

ទីកន្លែង: Regional Center, 5555 Road St., City, CA 90000

I. បញ្ហា

ថាតើមជ្ឈមណ្ឌលតំបន់ត្រូវតែបន្តផ្ដល់ថវិកាទ្រទ្រង់មជ្ឈមណ្ឌលតំបន់ត្រូវតែផ្ដល់សេវាប្រឹក្សាផ្នែកអប់រំដែលនឹងជួយ Sally X នៅក្នុងការទទួលបានសេវាអប់រំត្រឹមត្រូវតាមរយៈកម្មវិធីសិក្សារបស់សាលា។

II. សេចក្តីផ្តើម

Sally X គឺជាអ្នកប្រើប្រាស់/អ្នកជាវប្រចាំដែលមានអាយុ 14 ឆ្នាំរបស់មជ្ឈមណ្ឌលតំបន់ និងជាសិស្សនៃកម្មវិធីសិក្សាពិសេស។ Sally មានរោគស្លាប់អវៈយវៈទាក់ទងខួរក្បាល (cerebral palsy) និងធ្លាប់មានការវះកាត់ភ្ជាប់ឆ្អឹងកងចូលគ្នាដើម្បីឲ្យមាំ (spinal fusion surgery) កាលពីខែសីហា ឆ្នាំ 2015។ នាងធ្លាប់មានបញ្ហាចំពោះការទទួលបានសេវាកម្ម/អត្ថប្រយោជន៍ដែលនាងចាំបាច់ត្រូវការពីសាលារៀនឌីស្ត្រិករបស់នាង។ ដោយសារបញ្ហាលំបាកអស់ទាំងនេះ ទើប Sally និងក្រុមគ្រួសារនាងបានទទួលអត្ថប្រយោជន៍ច្រើនពីសេវាប្រឹក្សាផ្នែកអប់រំ។

កាលពីខែមករា ឆ្នាំ 2010 លោក ALJ Donald Cole បានកំណត់ច្បាស់លាស់ នៅក្រោយមានសវនការមួយដែលថា Sally ចាំបាច់ត្រូវការសេវាប្រឹក្សាផ្នែកអប់រំដែលនឹងជួយដល់ក្រុមគ្រួសារនាងក្នុងតស៊ូទទួលបានសេវាអប់រំត្រឹមត្រូវ។ Sally បន្តត្រូវការជំនួយរបស់ទីប្រឹក្សាអប់រំដែលទទួលបានថវិកាពីមជ្ឈមណ្ឌលតំបន់ (RC) ដែលតំណាងឲ្យ Sally នៅឯបណ្តាកិច្ចប្រជុំ IEP, ពិនិត្យតាមដានការអនុវត្ត IEP របស់សាលាឌីស្ត្រិក, និងផ្តល់ការប្រឹក្សាយោបល់ឲ្យដល់ក្រុមគ្រួសារនាង ក្នុងករណីដែលនាងត្រូវទទួលបានសេវាព្យាបាលដោយចលនានិយាយដែលនាងត្រូវការចាំបាច់ និងបន្តទទួលបានសេវាថែទាំព្យាបាលរាងកាយដែលនាងចាំបាច់ត្រូវការឲ្យមានសុវត្ថិភាពនៅសាលារៀន។

III. ហេតុផល

### A. មជ្ឈមណ្ឌលតំបន់ត្រូវតែផ្តល់សេវាប្រឹក្សាផ្នែកអប់រំដល់ SALLY ដើម្បីលើកយកមកដោះស្រាយនូវប្រភេទតម្រូវការដែលមានកំណត់នៅក្នុង IPP របស់នាង។

មជ្ឈមណ្ឌលតំបន់ចាំបាច់ត្រូវបង្កើតកម្មវិធីជំនួយសមត្ថភាពនៃបុគ្គលមានកម្សោយការចម្រើនខ្លួន និងក្រុមគ្រួសារ (IPP) សម្រាប់អ្នកប្រើប្រាស់/អ្នកជាវប្រចាំរបស់មជ្ឈមណ្ឌលតំបន់។ គម្រោងនេះត្រូវតែគិតដល់តម្រូវការរបស់អ្នកប្រើប្រាស់/អ្នកជាវប្រចាំផ្ទាល់ខ្លួន និងក្រុមគ្រួសាររបស់នាង។ ផ្នែកទី 4646 របស់ WIC ដើម្បីសម្រេចឱ្យបានវត្ថុបំណង របស់ IPP មជ្ឈមណ្ឌលតំបន់ មានភារកិច្ចធានាឱ្យមានសេវា និងការគាំទ្រនានា ទៅតាមសេចក្តីត្រូវការ ។ WIC section (ផ្នែក) 4648(a). សេវា និងការគាំទ្រនានា ដែលអាចមានផ្តល់ជូន អនុលោមតាម IPP រួមបញ្ចូល «advocacy assistance (ជំនួយផ្នែកតស៊ូមតិ)» WIC section (ផ្នែក) 4512(b).

មជ្ឈមណ្ឌលតំបន់ IPP ថ្មីបំផុត របស់ Sally X កាលពីថ្ងៃទី 27 ខែសីហា ឆ្នាំ 2015 បានទទួលស្គាល់ពីសេចក្តីត្រូវការរបស់គាត់ ក្នុងផ្នែកនានា ដែលគ្រួសាររបស់គាត់មានបំណងឱ្យមណ្ឌលសិក្សារបស់គាត់ ផ្តល់ដំណោះស្រាយឱ្យ ។ អនុលោមតាម IPP

របស់ Sally គាត់មិនអាចដើរបាន អាចធ្វើចលនាដៃ បានតិចតួច ត្រូវការជំនួយផ្នែករាងកាយ រួមទាំងការថែទាំសព្វបែបយ៉ាង និងមានបញ្ហាសុខភាព ដូចជា ទល់លាមក ពិបាកដកដង្ហើម និងមានប្រវត្តិធ្លាប់ប្រកាច់ ។ IPP របស់ Sally ទទួលស្គាល់ពីសារៈសំខាន់របស់សាលារៀន ក្នុងការបំពេញតាម សេចក្តីត្រូវការរបស់ Sally ។ IPP ពឹងផ្អែកលើការព្យាបាលផ្នែកនិយាយស្តី និងការអប់រំកាយមាន ការសម្របសម្រួល ដែលមានផ្តល់ជូនដោយសាលារៀនរបស់គាត់ ដើម្បីដោះស្រាយបញ្ហាក្នុងការប្រាស្រ័យទាក់ទង និងដើម្បីកែលំអ សមត្ថភាពរបស់គាត់ ក្នុងការគ្រប់គ្រងរាងកាយ និងប្រើដៃ ដើម្បីញ៉ាំអាហារ ដោយខ្លួនឯង ។ ដោយសារសាលារៀន គឺចំណុចស្នូល ក្នុងការបំពេញទៅតាម សេចក្តីត្រូវការ ឯកត្តជន របស់ Sally ដូចដែលមានទទួលស្គាល់ដោយ RC នៅក្នុង IPP របស់គាត់ និងដោយសារគ្រួសាររបស់ Sally ត្រូវការជំនួយ ពីទីប្រឹក្សាផ្នែកអប់រំ ដើម្បីទទួល បានសេវាអប់រំសមស្រប , RC មានភារកិច្ចផ្តល់ ទីប្រឹក្សាផ្នែកអប់រំ មួយរូប ដើម្បីផ្តល់សេវា ដល់ Sally ។

**B. មជ្ឈមណ្ឌលតំបន់ មានការទទួលខុសត្រូវ លើការជួយ SALLY ឱ្យទទួលបានធនធានទូទៅ រួមទាំងសេវានានា ដែលមានផ្តល់ ដោយមណ្ឌលសិក្សារបស់គាត់ ។**

មជ្ឈមណ្ឌលតំបន់ «ត្រូវកំណត់រក និងព្យាយាមស្វែងរកធនធាននានា តាមដែលអាចធ្វើទៅបាន ដើម្បីផ្តល់មូលនិធិ ដល់អ្នកប្រើប្រាស់ សេវារបស់មជ្ឈមណ្ឌលតំបន់ រួមទាំង មណ្ឌលសិក្សាផងដែរ។» WIC section (ផ្នែក) 4659(a)(1).

RC មានភារកិច្ច ធ្វើការព្យាយាមស្វែងរកមូលនិធិ ពីប្រភពទូទៅ ដើម្បីផ្តល់សេវាដែល Sally ត្រូវការ ។ នាពេលបច្ចុប្បន្ន គ្រួសាររបស់ Sally កំពុងព្យាយាមរក្សាឱ្យបាន នូវកម្រិតសមស្រប នៃការព្យាបាល ផ្នែកនិយាយស្តី នៅក្នុង IEP របស់ Sally ។ ការវះកាត់ភ្ជាប់ឆ្អឹងកងខ្នងរបស់ Sally បានផ្លាស់ប្តូរ យ៉ាងខ្លាំងដល់ស្ថានភាព ជំហរអង្គុយរបស់គាត់ នៅក្នុងកៅអីមានកង់ ហើយចាប់តាំងពីពេលវះកាត់រួច មក គាត់ចាប់ផ្តើមមានបញ្ហាជាច្រើន ចំពោះការគ្រប់គ្រងដង្ហើម នៅពេលនិយាយ ដោយគាត់ត្រូវអង្គុយឱ្យត្រង់ខ្លួន ។ ទោះជាយ៉ាងនេះក្តី មណ្ឌលសិក្សាបច្ចុប្បន្នរបស់គាត់ អះអាងថា ការនិយាយស្តី របស់គាត់ បានប្រសើរឡើងហើយ និងព្យាយាមកាត់បន្ថយ ឬលុបបំបាត់ សេវាព្យាបាល ផ្នែកនិយាយស្តីរបស់គាត់ ។ ទីប្រឹក្សា ផ្នែកអប់រំ របស់ Sally គឺស្ថិត ក្នុងដំណើរការជួយគ្រួសារគាត់ ធ្វើការព្យាយាមរក្សា ឱ្យមានការព្យាបាល ផ្នែកនិយាយស្តីរបស់គាត់ ។ ប្រសិនបើ Sally មិនអាចទទួលបានសេវាទាំងនេះ តាមរយៈសាលារៀននោះទេ គាត់អាចត្រូវស្វែងរកសេវាទាំងនេះ ពីមជ្ឈមណ្ឌលតំបន់ ដោយការបង់ថ្លៃសេវា ដែលជាជម្រើសចុងក្រោយ ។ ហេតុនេះ RC មានភារកិច្ចជួយ Sally ក្នុងការស្វែងរកធនធានទូទៅ ចំពោះការព្យាបាល ផ្នែកនិយាយស្តី ដែលមានផ្តល់មូលនិធិ ពីសាលារៀនរបស់គាត់ តាមរយៈសេវានានា ដែលមានផ្តល់ឱ្យជាបន្ត ពីទីប្រឹក្សា ផ្នែកអប់រំរបស់គាត់ ។

លើសពីនេះទៅទៀត ដោយសារតែស្ថានភាពសុខភាពទន់ខ្សោយ និងអសមត្ថភាព ផ្នែករាងកាយ របស់ Sally ដែលគាត់មិនអាចថែរក្សាខ្លួនឯងបាន ទើបកម្មវិធី មណ្ឌលសិក្សារបស់គាត់ តម្រូវឱ្យមានការតាមដានត្រួតពិនិត្យ ជាប្រចាំ ដើម្បីឱ្យ ប្រាកដថា គាត់ទទួលបានការថែទាំ ដែលគាត់ត្រូវការ នៅសាលារៀន ។ បើគ្មាន ការថែទាំនោះទេ គាត់ប្រាកដជាមិនអាចទៅសាលារៀនបាននោះដែរ ហើយនឹង ខកខានមិនបានទទួលសេវា ពីប្រភពធំៗ សម្រាប់អ្នកប្រើប្រាស់ មជ្ឈមណ្ឌល តំបន់ ដែលគ្រប់អាយុចូលរៀននោះឡើយ ។ មណ្ឌលសិក្សារបស់គាត់ ខកខានមិន បាន បំពេញតាមសេចក្ដីត្រូវការ ផ្នែករាងកាយ របស់គាត់ ជាច្រើនលើក ច្រើនសារ ដែលជាហេតុនាំគ្រោះថ្នាក់ ដល់សុខភាពរបស់គាត់ ។ ជំនួយជាបន្ត របស់ទីប្រឹក្សា ផ្នែកអប់រំ របស់គាត់ គឺមានត្រូវការជាចាំបាច់ ដើម្បីធានា ឱ្យមានសេវាត្រឹមត្រូវ ដូចមានបញ្ជាក់នៅក្នុង IEP របស់គាត់ និងប្រាកដថា មានការអនុវត្តតាម IEP របស់គាត់ ។

## C. មជ្ឈមណ្ឌលតំបន់ អាចផ្តល់មូលនិធិ ដល់សេវាទីប្រឹក្សា ផ្នែកអប់រំ ដើម្បីជួយ SALLY ឱ្យទទួលបានសេវា ពីមណ្ឌលសិក្សារបស់គាត់ ។

ជាទូទៅ មជ្ឈមណ្ឌលតំបន់ អាចមិនទិញ «សេវា [អប់រំ] សម្រាប់កុមារ ដែលមាន អាយុ បីឆ្នាំ ដល់ 17 ឆ្នាំ នោះទេ រួមទាំង កុមារគ្រប់អាយុផងដែរ» ប៉ុន្តែ អាចទិញ សេវានោះបាន ប្រសិនបើ «សេវានោះ ជាមធ្យោបាយចំបង ឬមធ្យោបាយចាំបាច់ ដើម្បីកែខៃឥទ្ធិពល ផ្នែករាងកាយ ផ្នែកស្មារតី ឬផ្នែកចិត្តសាស្រ្តសង្គម នៃពិការ ភាព ផ្នែកលូតលាស់ របស់អ្នកប្រើប្រាស់ ឬសេវានោះ មានលក្ខណៈចាំបាច់ ដើម្បីផ្ត ល់លទ្ធភាព ឱ្យអ្នកប្រើប្រាស់ អាច រស់នៅ ក្នុងផ្ទះគាត់ផ្ទាល់បាន ហើយគ្មាន ជម្រើសសេវាផ្សេងទៀត ដែលអាចបំពេញបានតាម សេចក្តីត្រូវការរបស់អ្នកប្រើ ប្រាស់ទេនោះ ។» WIC section (ផ្នែក) 4648.5(a)(3) និង (c).

RC បានបដិសេធ មិនផ្តល់មូលនិធិ ដល់សេវាទីប្រឹក្សា ផ្នែកអប់រំ របស់ Sally នោះ ទេ អនុលោមតាម WIC section (ផ្នែក) 4648.5 ។ ទោះជាយ៉ាងនេះក្តី section (ផ្នែក) 4648.5 មិនរារាំង RC មិនឱ្យផ្តល់មូលនិធិ ដល់សេវាទីប្រឹក្សា ផ្នែកអប់រំ ដែរ ដោយសារ ៖ 1) សេវា ដែលបានស្នើសុំ មិនមែនជា «សេវាអប់រំ» សម្រាប់កុមារ ដែល មាន អាយុ 3-17 នោះទេ បើគិតពីទម្លាប់ទូទៅ ហើយ 2) ទោះបីជា សេវាដែលបាន ស្នើសុំ មានលក្ខណៈ ជាសេវា «អប់រំ» សម្រាប់កុមារ ដែលមានអាយុ 3-17 ក៏ Sally មានលក្ខណៈសម្បត្តិ អាចទទួលបានការលើកលែងផងដែរ ។

## 1. សេវា ដែល SALLY ត្រូវការ មិនមែនជា សេវាអប់រំ សម្រាប់កុមារ ដែលមាន អាយុ 3 ដល់ 17 ឆ្នាំ នោះទេ ។ ហេតុនេះ ករណីនេះអាចទទួលបានមូលនិធិគាំទ្រ ពី SDRC ។

សេវា ដែលគ្រួសាររបស់ Sally ស្នើសុំ មិនមែនជា «សេវាអប់រំ» បើគិតពីទម្លាប់ទូទៅ ប៉ុន្តែជា សេវាទីប្រឹក្សា ឬសេវាគស្ម័មតិ ដើម្បីជួយ Sally ឱ្យទទួលបាន សេវាអប់រំសមស្រប តាមរយៈប្រភពទូទៅ ។ WIC section (ផ្នែក) 4648.5, ដែលបានអនុម័តឡើង ដើម្បីឆ្លើយតបទៅនឹង វិបត្តិសារពើពន្ធរបស់រដ្ឋកាលីហ្វ័រញ៉ា គឺជាការអនុវត្តជាក់លាក់ នៃវិធានទូទៅ ដែលមជ្ឈមណ្ឌលតំបន់ មិនគួរធ្វើការទូទាត់ លើសេវានានា ដែលមានផ្តល់ជូន អ្នកប្រើប្រាស់ តាមរយៈប្រភពទូទៅនោះទេ ។ ច្បាប់នេះ ហាមឃាត់ មជ្ឈមណ្ឌលតំបន់ មិនធ្វើការទូទាត់ លើការអប់រំ របស់អ្នកប្រើប្រាស់ នៅពេលអ្នកប្រើប្រាស់ គួរទទួលបានការអប់រំ ពីមណ្ឌលសិក្សា នៅមូលដ្ឋានរបស់ពួកគេនោះ ។ គ្រួសាររបស់ Sally មិនមែនស្នើសុំឱ្យ RC ធ្វើការទូទាត់ បុគ្គលណាម្នាក់ផ្សេងទៀត ដើម្បីមកបំពេញការងារ របស់មណ្ឌលសិក្សានោះទេ ប៉ុន្តែស្នើសុំឱ្យមានសេវាទីប្រឹក្សា ផ្នែកអប់រំ ដើម្បីជួួយ Sally ក្នុងការជំរុញ មណ្ឌលសិក្សារបស់គាត់ ឱ្យផ្តល់ការអប់រំដល់គាត់ ក្នុងលក្ខណៈមួយសមស្រប ។ សេវា ដែលបានស្នើសុំ នឹងបម្រើឱ្យគោលបំណងរបស់ section (ផ្នែក) 4648.5 ដោយធានាឱ្យ Sally បន្តទទួលបានសេវាសមស្រប ពីប្រភពទូទៅ ដែលត្រឹមត្រូវ ។

អាស្រ័យហេតុនេះ WIC section (ផ្នែក) 4648.5 មិនហាមឃាត់ ការទិញសេវាទីប្រឹក្សាផ្នែកអប់រំ សម្រាប់ Sally នោះទេ ហើយ RC គួរទិញ សេវាទាំងនោះ ក្នុងកិច្ចព្យាយាមស្វែងរកប្រភពមូលនិធិទូទៅ សម្រាប់សេវានានា ដែល Sally ត្រូវការ ។

## 2. ទោះបីជា សេវាដែល SALLY ត្រូវការ មានលក្ខណៈជា សេវា «អប់រំ» សម្រាប់កុមារ ដែលមានអាយុ 3-17 ក៏ Sally មានលក្ខណៈសម្បត្តិ អាចទទួលបាន ការលើកលែងផងដែរ ។

ទោះបីជា សេវាទីប្រឹក្សា ផ្នែកអប់រំ គឺជា «សេវាអប់រំ» សម្រាប់កុមារ ដែលមានអាយុ 3-17 ក៏ Sally មានលក្ខណៈសម្បត្តិ អាចទទួលបាន ការលើកលែង ពីការព្យួរអំណាចទិញដែរ ដោយសារសេវាដែលគាត់ស្នើសុំ មានលក្ខណៈចាំបាច់ ដែលអាចឱ្យគាត់មានលទ្ធភាពទទួលបានការអប់រំ ។ ដូចនេះ វាមានលក្ខណៈ សំខាន់ណាស់ សម្រាប់ការកែខៃឥទ្ធិពល នៃពិការភាពរបស់គាត់ ។  លើសពីនេះទៅទៀត គ្មានសេវា ជាជម្រើសផ្សេងទៀត ដែលអាចបំពេញបាន តាមសេចក្តីត្រូវការរបស់ Sally នោះទេ ។

សម្រាប់អ្នកប្រើប្រាស់ មជ្ឈមណ្ឌលតំបន់ ដែលមានសិទ្ធិទទួលបានសេវាអប់រំពិសេស សាលារៀននៅតែជាប្រភពចំបង នៃការផ្តល់សេវានានា ដើម្បីកែខៃ ឥទ្ធិពលនៃពិការភាពរបស់គាត់ ។ IPP ថ្មីបំផុតរបស់ Sally ទទួលស្គាល់ថា គាត់មានបញ្ហាសុខភាព ជាច្រើន ។ វា ក៏ពឹងផ្អែក យ៉ាងខ្លាំង លើកម្មវិធីសាលារៀនរបស់គាត់ ដើម្បីបំពេញតាម សេចក្តីត្រូវការនានារបស់គាត់ ។ ឧទាហរណ៍ វាផ្តល់ការពិភាក្សា លើ បញ្ហាផ្នែកនិយាយស្តីរបស់គាត់ ប៉ុន្តែមិនមាន រួមបញ្ចូល «លទ្ធផល» សម្រាប់ការនិយាយស្តីនោះទេ ដោយសារគាត់កំពុង ទទួលបាន ការព្យាបាល ផ្នែកនិយាយ

ស្ដី នៅសាលារៀន ហើយវាមានរួមបញ្ចូល លទ្ធផល ដែលតម្រូវឱ្យគាត់ ចូលរួម ក្នុង លំហាត់នានា នៅសាលារៀន ដើម្បីកសាងកម្លាំងរបស់គាត់ ដែលធ្វើឱ្យគាត់អាច រៀន ញ៉ាំអាហារ ដោយប្រើ សមបាន ដោយខ្លួនឯង ។

ការតស៊ូរបស់ Sally ជាមួយមណ្ឌលសិក្សារបស់គាត់ កន្លងមក បានបង្ហាញថា បុគ្គលម្នាក់ ត្រូវតែចូលរួម យ៉ាងមុតមាំ និងដោយយកចិត្តទុកដាក់ នៅក្នុង ដំណើរការ IEP របស់គាត់ ដើម្បីធានាឱ្យគាត់អាចរៀននៅសាលាបាន ប្រកបដោយ សុវត្ថិភាព ។ ពីដំបូងឡើយ សាលារៀនរបស់គាត់ បដិសេធ មិនធ្វើការសម្រួល បន្ទប់ទឹក នៅសាលារៀន ដើម្បីឱ្យគាត់អាចប្រើប្រាស់បាននោះទេ ហើយបញ្ហានេះ ត្រូវបាន ដោះស្រាយ ដោយសារតែមានការចូលរួមពី ទីប្រឹក្សា ផ្នែកអប់រំ របស់គាត់ តែប៉ុណ្ណោះ ។ Sally មានបញ្ហាស្ទះពោះវៀន នៅពេលគាត់រៀនថ្នាក់ទីប្រាំមួយ ដែល ម្ដាយ របស់គាត់គិតថា បញ្ហានេះបានកើតឡើង ដោយសារសាលារៀនមិនបាន យក គាត់ចេញពីកៅអីមានកង់ បានច្រើនដងនោះទេ (ដោយលើកហេតុផលថា ដោយសារគ្មានបុគ្គលិកគ្រប់គ្រាន់) ។ បញ្ហានេះ ក៏ត្រូវបានដោះស្រាយ ដោយទី ប្រឹក្សា ផ្នែកអប់រំ ផងដែរ ។

យ៉ាងហោចណាស់ Sally ចាំបាច់ត្រូវមានលទ្ធភាពអាចទៅសាលារៀនបាន ប្រកបដោយសុវត្ថិភាព ដោយសេវាសាលារៀនអាចកែខៃពិការភាពរបស់គាត់បាន ហើយសេវាទីប្រឹក្សា ផ្នែកអប់រំ របស់គាត់ នៅបន្តជួយធានាថា មណ្ឌលសិក្សា រក្សាឱ្យ គាត់ទទួលបានសុវត្ថិភាព និងសុខភាពល្អ នៅសាលារៀន ប៉ុន្តែកន្លងមក មណ្ឌល សិក្សា មានលក្ខណៈមិនអាចទុកចិត្តបាន ក្នុងការបំពេញតាម សេចក្តីត្រូវការ ផ្នែករាងកាយរបស់គាត់ ។ គាត់ ក៏មានសេចក្តីត្រូវការ ដែលមានការប្រែប្រួលជា និច្ច លើសេវានានា តាមរយៈ មណ្ឌលសិក្សា ដូចជា ការព្យាបាល ផ្នែកនិយាយស្ដី និងការអប់កាយ មានការសម្របសម្រួល ដើម្បីកែខៃឥទ្ធិពលនៃជម្ងឺប្រគ្រីវកាច់ (cerebral palsy) របស់គាត់ ។ គ្រួសារ X បានប្រយុទ្ធតស៊ូ ជាមួយមណ្ឌល ដើម្បី ទទួលបានសេវា ដែលគាត់ត្រូវការ ហើយពួកគេអាចធ្វើការតស៊ូទៅបាន លុះណាតែ មានការជួយពី ទីប្រឹក្សា ផ្នែកអប់រំ ។ ហេតុនេះ សេវាទីប្រឹក្សា ផ្នែកអប់រំ មានសារៈ សំខាន់ខ្លាំងណាស់ សម្រាប់ការកែខៃ ឥទ្ធិពលពិការភាពរបស់ Sally ។

ជាទីបញ្ចប់ គ្មានប្រភពជាជម្រើសផ្សេងទៀត ដើម្បីបំពេញសេចក្តីត្រូវការរបស់ Sally លើសេវាទីប្រឹក្សា ផ្នែកអប់រំ នោះទេ ។ ប្រភពទូទៅ ឬ ប្រភព «ជាជម្រើស» សម្រាប់សេវានានា ជូនអ្នកប្រើប្រាស់ ដែលភាគច្រើន ត្រូវបានរំពឹងចង់បាន យ៉ាង ច្បាស់ ដោយ WIC section (ផ្នែក) 4648.5 នោះ គឺមណ្ឌលសិក្សា របស់អ្នកប្រើប្រាស់ ។ មណ្ឌលសិក្សា របស់ Sally ខកខានមិនបានផ្តល់សេវាសមស្រប ដល់គាត់ ជា ច្រើនលើក ច្រើនសារ ។ គោលបំណងរបស់ ទីប្រឹក្សា ផ្នែកអប់រំ របស់គាត់ គឺដើម្បី អូសទាញ ឬជំរុញ មណ្ឌល ឱ្យផ្តល់នូវអ្វីៗ ដែល Sally ត្រូវការ ។

ខណៈដែលទីភ្នាក់ងារផ្សេងៗ ទៀត ដែលធ្វើការតស៊ូមតិ ដើម្បីសិស្ស ពាក់ព័ន្ធនឹង បញ្ហាអប់រំពិសេស មានវត្តមាននៅក្នុងសហគមន៍, ប្រភពជំនួយផ្សេងទៀត មិន មានសម្រាប់ Sally នោះទេ ។ Sally និងគ្រួសាររបស់គាត់ មានទំនាក់ទំនងការងារ ជាមួយទីប្រឹក្សា ផ្នែកអប់រំ បច្ចុប្បន្ន របស់គាត់ ក្នុងរយៈពេលជាយូរមកហើយ ដោយគ្រួសារគាត់ប្រើ សេវាទីប្រឹក្សារូបនេះ ដោយសារគាត់ គឺជាអ្នកលក់ របស់ RC ដែលត្រូវបានចាត់តាំង ឱ្យពួកគេ ដោយ RC ។ ប្រសិនបើ Sally ត្រូវចាប់ផ្តើមធ្វើ ការ ជាមួយបុគ្គលផ្សេងទៀត នាពេលនេះ នោះបុគ្គលថ្មីនេះ នឹងត្រូវចំណាយពេល ច្រើន ដើម្បីយល់ដឹង អំពីប្រវត្តិរបស់គាត់ ។ នេះ នឹងមិនសូវមានប្រសិទ្ធភាព ហើយវាទំនោរ ដែលថា បុគ្គលថ្មីអាចនឹងមិនយល់ អំពីសេចក្តីត្រូវការរបស់គាត់ បានពេញលេញ ដូចទីប្រឹក្សាបច្ចុប្បន្ន របស់គាត់ ។ អ្នកតស៊ូមតិថ្មី មួយរូប អាច នឹងមិនយល់ អំពីប្រវត្តិនៃការប្រយុទ្ធតស៊ូរបស់ Sally ជាមួយមណ្ឌលសិក្សា ឬមិន អាចទាញអត្ថប្រយោជន៍ ពីទំនាក់ទំនងការងារ របស់ទីប្រឹក្សាបច្ចុប្បន្នរបស់គាត់ ជាមួយមណ្ឌលនោះទេ ។

កិច្ចប្រជុំ IEP បន្ទាប់របស់ Sally គឺត្រៀមធ្វើឡើង នៅថ្ងៃទី 21 ខែកញ្ញា ឆ្នាំ 2015 ។ គាត់ត្រូវការជំនួយ ពីអ្នកតស៊ូមតិ ដែលស្គាល់ច្បាស់ ពីសេចក្តីត្រូវការរបស់គាត់ រួច ជាស្រេច នៅក្នុងកិច្ចប្រជុំ IEP នោះ និងនៅក្នុងការតាមដាន ក្រោយកិច្ចប្រជុំ នោះ ។ វាមានសារៈសំខាន់ ជាពិសេស ដែលទីប្រឹក្សា ផ្នែកអប់រំ បច្ចុប្បន្ន របស់គាត់ មានឱកាស អនុវត្តតាមដំណោះស្រាយ លើជម្លោះរបស់គាត់ ជាមួយមណ្ឌលសិក្សា ចំពោះការព្យាបាល ផ្នែកនិយាយស្តី តាមដែលគាត់បានចាប់ផ្តើមធ្វើការលើបញ្ហា នោះ ។

សេចក្តីសម្រេច ច្បាស់លាស់ របស់ ALJ Donald Cole នៅឆ្នាំ 2010 ដែលថា ស្ថាន ភាពរបស់ Sally មានលក្ខណៈខុសប្រក្រតី ហើយត្រូវការការចូលរួម ថេជាប្រចាំ ពីទី ប្រឹក្សា ផ្នែកអប់រំ ដើម្បីធានាអាចបំពេញបានតាម សេចក្តីត្រូវការរបស់គាត់ ។ នា ពេលនេះ សេចក្តីត្រូវការរបស់ Sally អាចបំពេញបាន តែតាមរយៈសេវាជាបន្ត ក្នុង រយៈពេលវែង ពីទីប្រឹក្សា ផ្នែកអប់រំរបស់គាត់ ។

## IV. សេចក្តីសន្និដ្ឋាន

Sally X ត្រូវការសេវារបស់ទីប្រឹក្សា ផ្នែកអប់រំ របស់គាត់ ដែលមានឧបត្ថម្ភ ដោយ មជ្ឈមណ្ឌលតំបន់ ដើម្បីជួយគាត់ ឱ្យទទួលបានធនធានទូទៅ ដ៏សំខាន់ គឺ សេវា អប់រំពិសេស តាមរយៈមណ្ឌលសិក្សារបស់គាត់ ។ RC មានភារកិច្ច ស្របច្បាប់ ក្នុង ការព្យាយាមស្វែងរកធនធានទូទៅនេះ សម្រាប់គាត់ ។ RC មិនត្រូវបានហាមឃាត់ មិនឱ្យធ្វើការស្វែងរកនេះទេ ដោយសារតែសេវាទីប្រឹក្សា ផ្នែកអប់រំ របស់ Sally មិន មែនជា «សេវាអប់រំ» សម្រាប់កុមារ ដែលមានអាយុ 3-17 ឆ្នាំ នោះទេ ។ លើសពីនេះ ទៅទៀត ទោះបីជាសេវាដែលគាត់ត្រូវការ ត្រូវបានចាត់ទុកថាជា សេវាអប់រំ ក៏ Sally នៅតែមានសិទ្ធិទទួលបានការលើកលែង ពីការដាក់កម្រិត លើការទិញសេវា

អប់រំនេះដែរ ដោយសារសេវានេះមានសារៈសំខាន់ សម្រាប់កែខៃ ឥទ្ធិពលពិការភាពរបស់គាត់ ហើយមិនអាចរកបាន ពីប្រភពជាជម្រើសផ្សេងទៀត នោះឡើយ ។ ដូចនេះ RC ត្រូវផ្តល់មូលនិធិ សម្រាប់សេវាទីប្រឹក្សា ផ្នែកអប់រំ សម្រាប់ Sally X ។

សូមដាក់ជូន ដោយក្តីគោរព ពី ៖

Bill X

ឪពុករបស់ Sally X

កាលបរិច្ឆេទ ៖

## ឧបសម្ព័ន្ធ E ៖ សេចក្តីសម្រេច ពីសវនការរដ្ឋបាល

នៅចំពោះមុខ ការិយាល័យទទួលបន្ទុកសវនការរដ្ឋបាល រដ្ឋកាលីហ្វ័រញ៉ា

ក្នុងករណីលើកលែង សម្រាប់

OAH No. 2015000000 ទីប្រឹក្សា ផ្នែកអប់រំ សម្រាប់ ៖

SALLY X.

អ្នកប្តឹងតវ៉ា,

និង

មជ្ឈមណ្ឌលតំបន់,

ទីភ្នាក់ងារផ្តល់សេវា ។

សេចក្តីសម្រេច

Mary Smith, ចៅក្រមច្បាប់រដ្ឋបាល, ការិយាល័យទទួលបន្ទុកសវនការរដ្ឋបាល បានស្តាប់ករណីនេះ នៅឡូសអេនជីឡេស កាលីហ្វ័រញ៉ា នៅថ្ងៃទី 12 ខែកញ្ញា ឆ្នាំ 2011 ។

Bill X., ឪពុករបស់ អ្នកប្តឹងតវ៉ា, តំណាងឱ្យ អ្នកប្តឹងតវ៉ា ដែលអវត្តមាន មិនបានមក ចូលរួមស្តាប់សវនការ ប្រកបដោយយុត្តិធម៌នេះ ។

Ryan M., Esq., តំណាងឱ្យ ទីភ្នាក់ងារផ្តល់សេវា គឺ មជ្ឈមណ្ឌលតំបន់ (RC) ។

ភស្តុតាង ជាពាក្យសម្តី និងជាឯកសារ ត្រូវបានទទួល ហើយករណីនេះ ត្រូវបានដាក់ជូន នៅថ្ងៃទី 12 ខែកញ្ញា ឆ្នាំ 2011 ។

បញ្ហា

1. តើមានការលើកលែង ក្រោម Welfare and Institutions Code (ក្រមសុខមាលភាព និងស្ថាប័ន) section (ផ្នែក) 4648.5 ដែលអនុញ្ញាតឱ្យ ទីភ្នាក់ងារផ្តល់សេវា ផ្តល់មូលនិធិគាំទ្រ សេវាទីប្រឹក្សា ផ្នែកអប់រំ របស់អ្នកប្តឹងតវ៉ា ដែរឬទេ ?

ការរកឃើញអង្គហេតុ

*បញ្ហាក្រោមបណ្តឹងតវ៉ា*

1. នៅថ្ងៃទី 5 ខែកក្កដា ឆ្នាំ 2011, RC បានផ្តល់សេវាដល់ អ្នកប្តឹងតវ៉ា ដោយមាន សេចក្តីជូនដំណឹង អំពីវិធានការ ដែលបានស្នើឡើង ដោយបដិសេធ មិនផ្តល់មូលនិធិ ដល់សេវាទីប្រឹក្សា ផ្នែកអប់រំ សម្រាប់អ្នកប្តឹងតវ៉ានោះទេ ។ នៅថ្ងៃទី 25 ខែកក្កដា ឆ្នាំ 2011, RC បានទទួលសំណើរបស់ អ្នកប្តឹងតវ៉ា សុំឱ្យ បើកសវនាការ ប្រកបដោយយុត្តិធម៌ ដែលជំទាស់នឹង ការសម្រេចរបស់ RC ហើយការតវ៉ានេះ មានបញ្ជាក់ជូនដូចខាងក្រោមនេះ ។

*សិទ្ធិទទួលបានសេវារបស់ អ្នកប្តឹងតវ៉ា និងសេវាដែលមានផ្តល់ឱ្យ នាពេលបច្ចុប្បន្ននេះ*

2. អ្នកប្តឹងតវ៉ា គឺជាកុមារី មានអាយុ 14 ឆ្នាំ ដែលមានធ្វើរោគវិនិច្ឆ័យឃើញថា មានជម្ងឺស្គន់ជាន់ (cerebral palsy) និងបញ្ហាខួរក្បាលលូតលាស់យឺតពេល (mental retardation) ។ អនុលោមតាម ដីកាបង្គាប់ ចុះថ្ងៃទី 7 ខែមករា ឆ្នាំ 2010 ដែលចេញដោយ សវនការរដ្ឋបាល មុន, នាពេលបច្ចុប្បន្ន RC ផ្តល់មូលនិធិគាំទ្រ សេវាទីប្រឹក្សា ផ្នែកអប់រំ ក្នុងរយៈពេល 16 ម៉ោង ក្នុងមួយខែ ដើម្បីជួយ អ្នកប្តឹងតវ៉ា លើផែនការអប់រំឯកត្តជន របស់គាត់ (IEP) ។

*Lanterman Act (ច្បាប់លេនធឺមែន) និងមជ្ឈមណ្ឌលតំបន់*

3. Lanterman Developmental Disabilities Services Act [the Lanterman Act] (ច្បាប់សេវាជនពិការ ផ្នែកលូតលាស់ លេនធឺមែន ហៅថា ច្បាប់លេធឺមែន) មានចែង នៅក្នុង Welfare and Institutions Code (ក្រមសុខមាលភាព និងស្ថាប័ន) section (ផ្នែក) 4500 et seq.

4. State Department of Developmental Services [the DDS] (ក្រសួងសេវាផ្នែកលូតលាស់ ប្រចាំរដ្ឋ) គឺជាទីភ្នាក់ងាររដ្ឋ នៅកាលីហ្វ័រញ៉ា ដែលទទួលខុសត្រូវលើ ការអនុវត្តច្បាប់នានា ពាក់ព័ន្ធនឹង ការថែទាំ ការបីបាច់ និងការព្យាបាល ឯកត្តជន ដែលមានពិការភាព ផ្នែកលូតលាស់ ក្រោម Lanterman Act (ច្បាប់លេនធឺមែន) ។i (Welf.& Inst.Code, section (ផ្នែក) 4416.) ដើម្បីបំពេញតាមអណត្តិការងារមានកំណត់ដោយច្បាប់ DDS ចុះកិច្ចសន្យា ជាមួយ ទីភ្នាក់ងារសហគមន៍ឯកជន ដែលមិនរកប្រាក់កម្រៃ ហៅថា «មជ្ឈមណ្ឌលតំបន់» ដើម្បីផ្តល់ «សេវា និងការគាំទ្រនានា ដល់ជនពិការ ផ្នែកលូតលាស់ ក្នុងលក្ខណៈសមស្របបំផុត សម្រាប់ពួកគេ ក្នុងកំឡុងពេលពេញ មួយអាយុកាលរបស់ពួកគេ» ។ (Welf.& Inst.Code, section (ផ្នែក) 4620.)

5. ការទទួលខុសត្រូវរបស់ មជ្ឈមណ្ឌលតំបន់ ចំពោះអ្នកប្រើប្រាស់សេវារបស់ខ្លួន គឺមានកំណត់ នៅក្នុង Welfare and Institutions Code (ក្រមសុខមាលភាព និងស្ថាប័ន) sections (ផ្នែក) 4640-4659 ។

*វិសោធនកម្ម ឆ្នាំ 2009 ចំពោះ Lanterman Act (ច្បាប់លេនធឺមែន)*

6. កាលីហ្វ័រញ៉ា ស្ថិតក្នុងស្ថានភាពកង្វះថវិកា ដែលមិនធ្លាប់មាន ពីមុនមក ។ គ្រប់ផ្នែករបស់រដ្ឋាភិបាល ប្រចាំរដ្ឋ ទទួលរងផលប៉ះពាល់ ពីវិបត្តិសារពើពន្ធនេះ រួមទាំង DDS ផងដែរ ។ សេចក្តីព្រាងច្បាប់ Assembly Bill 9 (AB 9) ត្រូវបានអនុម័ត ដែលនេះធ្វើវិសោធនកម្ម លើ Lanterman Act (ច្បាប់លេនធឺមែន) ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្របទៅតាម ការលំបាកផ្នែកសេដ្ឋកិច្ចនេះ ។ Section (ផ្នែក) 4648.5 ត្រូវបានបន្ថែម ទៅក្នុង Welfare and Institutions Code (ក្រមសុខមាលភាព និងស្ថាប័ន) ដែលមានចែងថា ៖

> "(a) ដោយមិនគិតពីបញ្ញត្តិផ្សេងៗ ទៀត នៃច្បាប់ ឬបទបញ្ញត្តិ ផ្ទុយពីខ្លឹមសារនេះ ដែលចូលជាធរមាន នៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2009, សិទ្ធិអំណាចរបស់ មជ្ឈមណ្ឌលតំបន់ ក្នុងការទិញសេវាខាងក្រោមនេះ ត្រូវព្យួរទុកសិន ដោយរង់ចាំ ការអនុវត្ត ថវិកាជម្រើសឯកត្តជន និងការបញ្ជាក់ ពីនាយកសេវា ផ្នែកលូតលាស់ ដែលថា ថវិកាជម្រើសឯកត្តជន ត្រូវបានអនុវត្ត ហើយនឹងធ្វើឱ្យមានការសន្សំ ថវិការដ្ឋ ដើម្បីរំលែកទៅចេញថ្លៃចំណាយ លើការផ្តល់សេវា ដូចខាងក្រោមនេះ ៖

(1) សេវាបោះជម្រំ និងថ្លៃចំណាយលើការធ្វើដំណើរ ដែលពាក់ព័ន្ធ

(2) សកម្មភាពកំសាន្ត លក្ខណៈសង្គម លើកលែងសកម្មភាព ដែលមានលក់ ជាកម្មវិធីពេលថ្ងៃ នៅតាមសហគមន៍ (community-based day programs) ។

(3) សេវាអប់រំ សម្រាប់កុមារ មានអាយុបីឆ្នាំ ដល់ 17 ឆ្នាំ រួមទាំង យុវជនគ្រប់អាយុ ។

(4) ការព្យាបាល មិនមែនលក្ខណៈវេជ្ជសាស្ត្រ រួមទាំង តែមិនកំណត់ត្រឹម ការកំសាន្តលក្ខណៈឯកទេស សិល្បៈ របាំ និងតន្ត្រី ។

(b) សម្រាប់អ្នកប្រើប្រាស់សេវា មជ្ឈមណ្ឌលតំបន់ ដែលទទួលបានសេវា ដូចមានរៀបរាប់ នៅផ្នែករង (a) ជាផ្នែកនៃ ផែនការកម្មវិធីឯកត្តជនរបស់ពួកគេ (IPP) ឬ ផែនការសេវាគ្រួសារ លក្ខណៈឯកត្តជន (IFSP), ការហាមឃាត់ នៅក្នុង ផ្នែករង (a) ត្រូវចូលជាធរមាន នៅថ្ងៃទី 1 ខែសីហា ឆ្នាំ 2009 ។

(c) ការលើកលែង អាចត្រូវផ្តល់ឱ្យ ផាលក្ខណៈឯកត្តជន ដែលស្ថិតក្នុងស្ថានភាព វិសាមញ្ញ ដើម្បីអនុញ្ញាតឱ្យ ទិញសេវា ដូចមានកំណត់រកឃើញ នៅក្នុងផ្នែករង (a) នៅពេល មជ្ឈមណ្ឌលតំបន់ កំណត់ថា សេវានោះ គឺជាមធ្យោបាយ ចំបង ឬមាន សារៈសំខាន់ សម្រាប់កែខៃឥទ្ធិពល ផ្នែករាងកាយ ផ្នែកស្មារតី ឬផ្នែកចិត្តសាស្ត្រ សង្គម នៃពិការភាព ផ្នែកលូតលាស់ របស់អ្នកប្រើប្រាស់ ឬសេវានោះ មានលក្ខណៈ ចាំបាច់ ដែលធ្វើឱ្យ អ្នកប្រើប្រាស់ អាចនៅក្នុងផ្ទះរបស់ គាត់ផ្ទាល់បាន ហើយគ្មាន សេវាជាជម្រើសផ្សេងទៀត ដែលអាចបំពេញតាម សេចក្តីត្រូវការនេះបាន ។»

ផ្នែកនៃក្រមថ្មីនេះ មិនបានកំណត់ ពី «ស្ថានភាព វិសាមញ្ញ» ហើយមិនបាន ចង្អុលបង្ហាញ អំពីអ្វីដែលនឹងបង្កើត «ជាមធ្យោបាយចំបង ឬមានសារៈសំខាន់ សម្រាប់កែខៃ» ពិការភាព ផ្នែកលូតលាស់ របស់អ្នកប្រើប្រាស់ ដើម្បីជួយ អ្នកប្រើ ប្រាស់ឱ្យអាចបន្ត ទទួលបានសេវាទាំងនេះ ដោយប្រហែលជា ទុកការកំណត់នេះ ឱ្យ មជ្ឈមណ្ឌលតំបន់ និងអ្នកលើកអង្គហេតុតវ៉ា តាមករណី ជាអ្នកធ្វើការសន្និដ្ឋាន ហើយមើលទៅ ។

*ភស្តុតាងដែលបង្ហាញប្រាប់នៅក្នុងអង្គសវនការ*

7. Warren W., អ្នកគ្រប់គ្រងកម្មវិធីរបស់ RC, បានផ្តល់កសិណសាក្សីថា អ្នកប្តឹង តវ៉ា មាន «ការប្រែប្រួលស្ថានភាព» ដោយ នាពេលថ្មីៗ នេះ គាត់បានចាប់ផ្តើម ចូលរៀន នៅថ្នាក់អនុវិទ្យាល័យ (middle school) ផ្សេងទៀត ដែលនាំឱ្យគាត់លែង ត្រូវការ សេវាទីប្រឹក្សា ផ្នែកអប់រំ ដោយសារបញ្ហាដែលគាត់មាន គឺនៅសាលារៀន ចាស់ របស់គាត់ ។ គាត់ក៏បានផ្តល់កសិណសាក្សីថា ទោះបីជា ទីប្រឹក្សា ផ្នែកអប់រំ បច្ចុប្បន្ន របស់ អ្នកប្តឹងតវ៉ា គឺ Deborah P. ជាអ្នកលក់របស់ RC ក៏គាត់ខកខាន មិនបានផ្តល់ របាយការណ៍វឌ្ឍនភាព បានទាន់ពេលវេលានោះទេ ដែលជាហេតុធ្វើ ឱ្យ RC លែងចង់ប្រើសេវារបស់គាត់ទៀត ។ ប៉ុន្តែ គាត់ទទួលស្គាល់ថា RC បានបន្ត ផ្តល់មូលនិធិ ដល់សេវារបស់គាត់ ក្នុងកំឡុងពេលដែលគាត់ខកខាន មិនបានផ្តល់ របាយការណ៍ ។

8. ឪពុកម្តាយរបស់ អ្នកប្តឹងតវ៉ា បានផ្តល់កសិណសាក្សី ដែលអាចជឿជាក់បាន និងសមហេតុផល អំពីការប្រយុទ្ធតស៊ូ ជាប្រចាំ របស់ពួកគេ ជាមួយមណ្ឌលសិក្សា របស់ អ្នកប្តឹងតវ៉ា និងដើម្បីជំរុញឱ្យមណ្ឌលសិក្សា ផ្តល់សេវានានា តាមការតម្រូវ ដោយច្បាប់ និងដូចមានបញ្ជាក់ នៅក្នុង IEP ។ ពួកគេ ក៏បានពន្យល់ថា Deborah P. មានការយល់ដឹងជិតដល់ អំពីស្ថានភាពរបស់ អ្នកប្តឹងតវ៉ា, ធ្លាប់បានជួយឱ្យ ទទួលបានសេវា ដែលត្រូវការ និងជាផ្នែកមួយ ដ៏សំខាន់ នៃដំណើរការ IEP របស់ អ្នកប្តឹងតវ៉ា ។ ទោះបីជាទៅរៀននៅសាលាថ្មីក៏ដោយ ក៏សេវាត្រូវត្រូវការទាំងអស់ ដូចមានបញ្ជាក់ នៅក្នុង IEP នៅមិនទាន់បានអនុវត្តនៅឡើយ ។ លើសពីនេះទៅ ទៀត នាពេលបច្ចុប្បន្ននេះ អ្នកប្តឹងតវ៉ា និងមណ្ឌលសិក្សា មានការមិនចុះសម្រុង

គ្នា ចំពោះសេវា ផ្នែកនិយាយស្ដីរបស់គាត់ ។ ហេតុនេះ អន្តរកាល នៃការចូលរៀន នៅសាលាថ្មី មិនមានលក្ខណៈរលូន នោះទេ ។

*ការវាយតម្លៃ*

9. ឧត្តមានុភាពនៃភស្តុតាង បានបញ្ជាក់ថា អ្នកប្ដឹងតវ៉ា មានសិទ្ធិទទួលបាន ការលើកលែង ក្រោម Welfare and Institutions Code (ក្រមសុខមាលភាព និងស្ថាប័ន) section (ផ្នែក) 4648.5, subdivision [ផ្នែករង] (c) ។ មានបង្ហាញ ភស្តុតាង មិនគ្រប់គ្រាន់ ដើម្បីបញ្ជាក់ថា អ្នកប្ដឹងតវ៉ា លែងត្រូវការ សេវាដែលតម្រូវឱ្យមាន ពីទីប្រឹក្សា ផ្នែកអប់រំ ។ ទោះជាដោយសារហេតុផលណាក៏ដោយ មណ្ឌលសិក្សារបស់ អ្នកប្ដឹងតវ៉ា ហាក់ដូចជាដើរតួជា ដៃគូខ្វះវិន័យ នៅក្នុងការអប់រំគាត់ ហើយអាចសម្រេចបាន តែតាមរយៈ សកម្មភាពរបស់ Deborah P. ដែលមណ្ឌលបានសហការជាមួយ តែប៉ុណ្ណោះ ។ ការបញ្ចប់សេវារបស់គាត់ នាពេលនេះ នឹងបង្កការលំបាកធ្ងន់ធ្ងរ ដល់ អ្នកប្ដឹងតវ៉ា និងគ្រួសារគាត់ ។ RC ខកខានមិនបានបញ្ជាក់ ពីផ្លាស់ប្ដូរស្ថានភាព ឱ្យបានគ្រប់គ្រាន់ ដើម្បីបដិសេធ ចោល ដីកាបង្គាប់ពីមុន របស់តុលាការនេះ ដែលមានបញ្ជាក់ពី ការលើកលែង សម្រាប់ការផ្ដល់សេវាអប់រំ នោះទេ ។ រាល់បញ្ហារវាង RC និង Deborah P. ពាក់ព័ន្ធនឹងការខកខានរបស់គាត់ ក្នុងការផ្ដល់ របាយការណ៍វឌ្ឍនភាព ឱ្យបានទាន់ពេល ត្រូវបានចាត់ទុកថាជា បញ្ហាផ្ទៃក្នុងរបស់ អ្នកលក់ ដែលអាចនាំឱ្យ RC បង្កកការទូទាត់ប្រាក់ឱ្យគាត់ លុះណាតែទទួលបាន របាយការណ៍ ។ ប៉ុន្តែ នេះមិនគួរក្លាយជាការដាក់ទណ្ឌកម្ម ដល់ អ្នកប្ដឹងតវ៉ា ដោយការបញ្ឈប់គាត់មិនឱ្យបម្រើការងារនោះទេ ។

សេចក្ដីសន្និដ្ឋានតាមនិត្យានុកូលដ្ឋានច្បាប់

*បន្ទុករក្សាភស្តុតាង*

1. នៅក្នុងដំណើរការរដ្ឋបាល ដូចនៅក្នុងវិធានការស៊ីវិលធម្មតា ជាទូទៅ ភាគីដែលធ្វើការអះអាង មានបន្ទុកផ្ដល់ភស្តុតាង រួមទាំងបន្ទុកពន្យល់បង្ហាញ តាមរយៈឧត្តមានុភាពនៃភស្តុតាង ។ (McCoy v. Board of Retirement [គណៈកិច្ចការចូលនិវត្តន៍] (1986) 183 Cal.App.3d 1044, 1051-1052.) RC មានបន្ទុកក្នុងការបញ្ជាក់ថា ការលើកលែង សម្រាប់សេវាផ្នែកអប់រំ លែងមានវត្តមានទៀតហើយ ។

*Lanterman Act (ច្បាប់លេនធឺមែន)*

2. ច្បាប់ ដែលដាក់ឱ្យប្រើប្រាស់ comprehensive statutory scheme (គម្រោងច្បាប់ទូលំទូលាយ) ហៅថា Lanterman Developmental Disabilities Services Act (ច្បាប់សេវាជនពិការ ផ្នែកលូតលាស់ លេនធឺមែន) ដើម្បីផ្ដល់បែបផែន នៃសម្បទា និងសេវានានា ដែលមានលក្ខណៈគ្រប់គ្រាន់ពេញលេញ ក្នុងការបំពេញតាម សេច

ក្តីត្រូវការរបស់ជនពិការ ផ្នែកលូតលាស់ ម្នាក់ៗ ដោយមិនគិតពី អាយុ ឬកម្រិតពិការភាព និងដំណាក់កាលណាមួយ នៃជីវិត ។ គោលបំណងរបស់ statutory scheme (គម្រោងច្បាប់) នេះ មាន ពីរផ្នែក គឺ ដើម្បីបង្ការ ឬកាត់បន្ថយ ឱ្យនៅកម្រិតអប្បបរមា ចំពោះការដាក់ជនពិការឱ្យនៅកន្លែងណាមួយ និងការផ្តាច់ពួកគេ ចេញពីគ្រួសារ និងសហគមន៍ ហើយជួយពួកគេឱ្យ ដឹងឮពី បែបផែននៃការរស់នៅ ជាប្រចាំថ្ងៃ របស់ជនដែលគ្មានពិការភាព ក្នុងវ័យដូចពួកគេ ហើយឱ្យពួកអាចរស់នៅបាន ដោយឯករាជ្យ និងមានផលិតភាព ប្រសើរឡើង នៅក្នុងសហគមន៍ ។ (Association for Retarded Citizens [សមាគមប្រជាពលរដ្ឋមានការលូតលាស់យឺត] v. Department of Developmental Services [ក្រសួងសេវា ផ្នែកលូតលាស់] (1985) 38 Cal.3d 384, 388.) វាជាការសំខាន់ ដែលត្រូវកត់សម្គាល់ថា គ្មានសេវាណាមួយ ដែលបានស្នើសុំដោយ អ្នកប្តឹងតវ៉ា មានលក្ខណៈមិនសមហេតុផល ឬមិនពាក់ព័ន្ធនឹងស្ថានភាព របស់គាត់នោះទេ ។ តាមពិត សេវាជាច្រើន ត្រូវបានផ្តល់ជូន តាម IEP នីមួយៗ ហើយដោយសារ ហេតុផល ដែលនៅតែខ្វះភាពច្បាស់លាស់ មណ្ឌលសិក្សា បានបដិសេធមិនអនុវត្ត សេវាទាំងនោះ ។

3. បញ្ញត្តិពាក់ព័ន្ធ នៃ Lanterman Developmental Disabilities Services Act (ច្បាប់សេវាជនពិការ ផ្នែកលូតលាស់ លេនធឺមែន) មានរួមបញ្ចូល នៅក្នុង ឯកសារ របកគំហើញអង្គហេតុ ។

*បុព្វហេតុ មានវត្តមាន ចំពោះការផ្តល់ជូន និងសំណើឱ្យមានការលើកលែង សម្រាប់ សេវាទីប្រឹក្សា ផ្នែកអប់រំ*

*ទីប្រឹក្សា (Consultant)*

4. ឧត្តមានុភាពនៃភស្តុតាង បានបញ្ជាក់ថា RC គួរបន្តផ្តល់មូលនិធិ ដល់សេវាទីប្រឹក្សា ផ្នែកអប់រំ សម្រាប់អ្នកប្តឹងតវ៉ា ។ អ្នកប្តឹងតវ៉ា បានបន្តបង្ហាញភស្តុតាងគ្រប់គ្រាន់ ដើម្បីធានាឱ្យមាន ការលើកលែង សម្រាប់សេវានេះ ។

ដីកាបង្គាប់

សំណើរបស់ អ្នកប្តឹងតវ៉ា សុំឱ្យមានការលើកលែង អនុលោមតាម Welfare and Institutions Code (ក្រមសុខមាលភាព និងស្ថាប័ន) section (ផ្នែក) 4648.5, subdivision [ផ្នែករង] (c), ត្រូវបានសម្រេចផ្តល់ជូន ។ RC ត្រូវបន្តផ្តល់មូលនិធិដល់សេវាទីប្រឹក្សា ផ្នែកអប់រំ តាមសំណើរបស់ អ្នកប្តឹងតវ៉ា ។

កាលបរិច្ឆេទ ៖ 23 កញ្ញា 2011

MARY SMITH

ចៅក្រមច្បាប់រដ្ឋបាល

ការិយាល័យទទួលបន្ទុកសវនាការផ្លូវការ

**សេចក្តីជូនដំណឹង**

**នេះ គឺជាសេចក្តីសម្រេចរដ្ឋបាលស្ថាពរ ។ គូភាគី ត្រូវគោរពតាមសេចក្តីសម្រេចនេះ ។ ភាគីនីមួយៗ អាចប្តឹងតវ៉ា ចំពោះសេចក្តីសម្រេចនេះ ទៅតុលាការ ដែលមានអំណាចយុត្តាធិការបាន ក្នុងរយៈពេល កៅសិបថ្ងៃ ។**

*គម្រោងការណ៍ការពារ & គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ាទទួលបានការឧបត្ថម្ភថវិកាពីប្រភពជាច្រើន សម្រាប់បញ្ជីអ្នកឧបត្ថម្ភថវិកាពេញលេញ ឆ្ពោះទៅកាន់ទំព័រដែលមានតំណ* http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html។